ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

# របាយការណ៍វាយតម្លៃពេញលេញលើសេចក្តីព្រាង
# ប្រកាសស្តីពីការបង្កើត និងការគ្រប់គ្រងកសិដ្ឋានចិញ្ចឹមសត្វ

រៀបចំដោយ
ទីភ្នាក់ងារអនុវត្តគម្រោងវាយតម្លៃលើផលប៉ះពាល់នៃលិខិតបទដ្ឋានគតិយុត្ត
នៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទដោយមានការផ្តល់យោបល់ពី
ក្រុមការងារប្រតិបត្តិគម្រោងវាយតម្លៃលើផលប៉ះពាល់នៃលិខិតបទដ្ឋានគតិយុត្ត
នៃក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌នៃទីស្តីការគណៈរដ្ឋមន្ត្រី

ខែសីហា ឆ្នាំ២០១៥

**ទំនាក់ទំនង**

**អង្គភាព៖** ទីភ្នាក់ងារអនុវត្តគម្រោងវាយតម្លៃផលប៉ះពាល់លើលិខិតបទដ្ឋានគតិយុត្ត
នៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

**បុគ្គលទទួលបន្ទុក៖** លោក **អ៊ុំ សាវី**

**តួនាទី៖** អនុប្រធាននាយកដ្ឋានបុគ្គលិកនិងអភិវឌ្ឍន៍ធនធានមនុស្សនិងជាប្រធានក្រុមការងារអនុវត្តគម្រោងវាយតម្លៃលើផលប៉ះពាល់នៃលិខិតបទដ្ឋានគតិយុត្ត

**អាសយដ្ឋាន៖** អគារលេខ២០០ មហាវិថីព្រះនរោត្តម សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមនរាជធានីភ្នំពេញ

**ទំនាក់ទំនងទូរស័ព្ទ៖** (៨៥៥) ១២ ៧២៧ ៦៦៤

E-mail: savy.sokunthea@gmail.com

**គេហទំព័រ៖** www.maff.gov.kh

**អង្គភាព/ស្ថាប័នឆ្លងឯកសារ**

១.ការណែនាំរបស់ថ្នាក់ដឹកនាំក្រសួង ឱ្យធ្វើការសិក្សាវាយតម្លៃផលប៉ះពាល់លើសេចក្តីព្រាងប្រកាសនេះ។

២.ឆ្លងយោបល់ពីក្រុមការងារប្រតិបត្តិគម្រោងវាយតម្លៃលើផលប៉ះពាល់នៃលិខិតបទដ្ឋានគតិ-យុត្ត របស់ក្រុមប្រឹក្សា សេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌នៃទីស្តីការគណ: រដ្ឋមន្ត្រី។

៣.ឆ្លងយោបល់ពីទីភ្នាក់ងារអនុវត្តគម្រោងវាយតម្លៃផលប៉ះពាល់លើលិខិតបទដ្ឋានគតិយុត្តនៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។

៤.ពិគ្រោះយោបល់ជាមួយសមត្ថកិច្ចពាក់ព័ន្ធនៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងជាមួយផ្នែកឯកជន។

**កាលបរិច្ឆេទនៃការរៀបចំ**

កាលបរិច្ឆេទចាប់ផ្តើម:ថ្ងៃទី១៥ ខែឧសភា ឆ្នាំ២០១៥

កាលបរិច្ឆេទបញ្ចប់ :ថ្ងៃទី១៥ ខែតុលា ឆ្នាំ២០១៥

ឯកសារនេះ ជាការសិក្សារៀនសូត្ររបស់ក្រុមការងារវាយតម្លៃលើផលប៉ះពាល់ នៃលិខិតបទ-ដ្ឋានគតិយុត្តក្រសួងកសិកម្ម រុក្ខាប្រមាញ់និងនេសាទ ដោយមានការផ្តល់យោបល់ពីគម្រោងវាយតម្លៃលើផលប៉ះពាល់នៃលិខិតបទដ្ឋានគតិយុត្តរបស់ក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ចនិងវប្បធម៌ នៃទីស្តីការគណ:រដ្ឋមន្ត្រី។

# មាតិកា

**អតិប្បាយសង្ខេប** ........ **០១**
**១.ការកំណត់បញ្ហា**........ **០៤**
១.១សុខភាព និងសុវត្ថិភាពសាធារណៈ ........ **០៤**
១. ២.ការការពារបរិស្ថាន ........ **០៤**
១.៣.ការប្រកួតប្រជែង........ **០៤**
១.៤.ការគ្រប់គ្រងព័ត៌មាន និងទិន្នន័យនៃការចិញ្ចឹមសត្វ ........ **០៥**
១.៥.កង្វះលិខិតបទដ្ឋានគតិយុត្តសម្រាប់គ្រប់គ្រងការចិញ្ចឹមសត្វ........ **០៥**
**២.គោលបំណង កាតព្វកិច្ច និងវិសាលភាព**........ **០៧**
២.១. គោលបំណង........ **០៧**
២.២. កាតព្វកិច្ច និងវិសាលភាព........ **០៧**
**៣.ជម្រើស**........ **០៨**
៣.១.ជម្រើសទី១........ **០៨**
៣.២.ជម្រើសទី២........ **០៨**
**៤.ការវិភាគផលប៉ះពាល់**........ **០៩**
៤.១.ជម្រើសទី១៖ រក្សាស្ថានភាពដើម ដោយពង្រឹងការអនុវត្តលិខិតបទដ្ឋានដែលមានស្រាប់........ **០៩**
៤.២.ជម្រើសទី២៖ រៀបចំសេចក្តីព្រាងប្រកាសស្តីពីការបង្កើតនិងការគ្រប់គ្រងកសិដ្ឋានចិញ្ចឹមសត្វ........ **១០**
**៥. ការពិគ្រោះយោបល់**........ **១៤**
៥.១. ពិគ្រោះយោបល់ជាមួយផ្នែកសាធារណៈ........ **១៤**
៥.២. ពិគ្រោះយោបល់ជាមួយផ្នែកឯកជន........ **១៧**
**៦. សន្និដ្ឋាន**........ **២២**
**៧. ការអនុវត្ត តាមដាន និងការវាយតម្លៃ**........ **២៤**
**ឧបសម្ព័ន្ធទី១ : បញ្ជីសំណួរ**
**ឧបសម្ព័ន្ធទី២: ឯកសារយោង**
**ឧបសម្ព័ន្ធទី៣: សេចក្តីព្រាងប្រកាសស្តីពីការបង្កើតនិងការគ្រប់គ្រងកសិដ្ឋានចិញ្ចឹមសត្វ**
**ឧបសម្ព័ន្ធទី៤: តារាងគណនាបន្ទុកចំណាយ**

## អធិប្បាយសង្ខេប

របាយការណ៍វាយតម្លៃពេញលេញលើផលប៉ះពាល់នៃសេចក្តីព្រាងប្រកាសស្តីពីការបង្កើត និងការគ្រប់គ្រងកសិដ្ឋានចិញ្ចឹមសត្វ ដែលរៀបចំឡើងដោយក្រុមការងារRIAរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់និងនេសាទ នឹងផ្តល់ពត៌មានអំពីផលប៉ះពាល់និងជម្រើសផ្សេងៗ តាមវិធីសាស្ត្ររបស់RIA សម្រាប់ជូនថ្នាក់ដឹកនាំក្រសួង ដើម្បីពិនិត្យ និងសម្រេច។

ខ្លឹមសារនិងអត្ថន័យសំខាន់ៗនៃរបាយការណ៍នេះ មានដូចខាងក្រោមៈ

**ការកំណត់បញ្ហាៈ** ការចិញ្ចឹមសត្វភាគច្រើនមានទ្រង់ទ្រាយជាលក្ខណៈគ្រួសារ រីឯការចិញ្ចឹមបែបពាក់កណ្តាលឧស្សាហកម្មនិងឧស្សាហកម្មមានចំនួនតិចតួច ដែលកម្ពុជានៅមិនទាន់អាចផ្គត់ផ្គង់សាច់សត្វសម្រាប់បំពេញតម្រូវការក្នុងប្រទេសបាននៅឡើយ ដែលធ្វើឲ្យកម្ពុជាចាំបាច់ត្រូវមានការនាំចូលសាច់សត្វ សត្វរស់ និងស៊ុតពីក្រៅប្រទេស។ ទន្ទឹមនឹងនេះដែរ សមត្ថភាពប្រកួតប្រជែងលើការចិញ្ចឹមសត្វនៅកម្ពុជា នៅទន់ខ្សោយដោយសារថ្លៃដើមនៃការចញ្ចឹមមានកម្រិតខ្ពស់មិនអាចប្រកួតជាមួយសត្វដែលនាំចូលពីក្រៅប្រទេសបាន។ ម្យ៉ាងទៀតលំហូរនៃការនាំចូលសាច់សត្វ សត្វរស់និងស៊ុតពីក្រៅប្រទេស ក៏បានធ្វើឲ្យមានផលប៉ះពាល់អវិជ្ជមានដល់ការចិញ្ចឹមសត្វក្នុងស្រុកផងដែរ។ ក្រៅពីកត្តាផលិតកម្មសត្វ និងកត្តាសមត្ថភាពនៃការចិញ្ចឹមនៅមានកម្រិតកម្ពុជាក៏នៅមានបញ្ហាប្រឈមលើការគ្រប់គ្រងនៃការរីករាលដាលនៃជំងឺឆ្លងសត្វ ផលប៉ះពាល់បរិស្ថាន និងការគ្រប់គ្រងព័ត៌មាន និងទិន្នន័យនៃការចិញ្ចឹមសត្វ ព្រោះកម្ពុជានៅមិនទាន់មានលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងការគ្រប់គ្រងការចិញ្ចឹមសត្វនៅឡើយទេ។

**គោលបំណងៈ** ប្រកាសនេះមានគោលបំណងកំណត់អំពីការបង្កើតនិងការគ្រប់គ្រងកសិដ្ឋានចិញ្ចឹមសត្វដើម្បីបង្កើនផលិតភាពសត្វ ទប់ស្កាត់ការរីករាលដាលជំងឺសត្វ ការពារសុខភាពសត្វ សុខមាលភាពសត្វ សុខភាពសាធារណៈ និងបរិស្ថាន ។ គោលបំណងនេះ ស្របនឹងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៣ របស់រាជរដ្ឋាភិបាលនៅក្នុងចតុកោណទី១ ដែលកំណត់អំពីការលើកស្ទួយវិស័យកសិកម្ម ក្នុងនោះ មាននិយាយពីការលើកកម្ពស់ចលនាចិញ្ចឹមសត្វ ឲ្យកាន់តែទូលំទូលាយថែមទៀត។

**ជម្រើសៈ** តាមវិធីសាស្ត្រRIA មានជម្រើសចំនួន២ ត្រូវបានយកមកធ្វើការសិក្សានិងវាយតម្លៃពេញលេញអំពីផលប៉ះពាល់លើសេចក្តីព្រាងប្រកាសដែលបានរៀបចំឡើង ក្នុងនោះ ជម្រើសទី១« រក្សាស្ថានភាពដើម ដោយបន្តពង្រឹងការអនុវត្តលិខិតបទដ្ឋានដែលមានស្រាប់ » និងជម្រើសទី២ « រៀបចំសេចក្តីព្រាងប្រកាសស្តីពីការបង្កើត និងការគ្រប់គ្រងកសិដ្ឋានចិញ្ចឹមសត្វ» ដើម្បីប្រៀបធៀបរកឲ្យឃើញនូវផលប៉ះពាល់ ។

**ការវិភាគផលប៉ះពាល់ៈ** តាមការវិភាគផលប៉ះពាល់ គេអាចសន្និដ្ឋានបានថា ជម្រើសទី២ មានបន្ទុកចំណាយខ្ពស់ទាំងរដ្ឋនិងធុរកិច្ច ដែលក្នុងនោះ នៅឆ្នាំដំបូង ធុរកិច្ចបានចំណាយភាគច្រើនលើការសាងសង់ ប៉ុន្តែបើដកបន្ទុកចំណាយលើការសាងសង់នៅឆ្នាំដំបូងចេញ នោះកសិដ្ឋានមួយជាមធ្យម បានថយបន្ទុកចំណាយ មកនៅត្រឹមប្រមាណ៩.៥០០ដុល្លារ ស្មើនឹងប្រមាណ១៥,៩១% ប៉ុណ្ណោះ។ ទន្ទឹមជាមួយគ្នានេះដែរ គេក៏សង្កេតឃើញមានផលចំណេញចម្បងៗដល់សង្គមមានដូចជាការការពារបរិស្ថាន និងការទប់ស្កាត់បាននូវការរីករាលដាលនៃជំងឺឆ្លងសត្វ ការបង្កើតការងារក្នុងស្រុកជូនប្រជាពលរដ្ឋខ្មែរ ការធ្វើឲ្យកម្ពុជាអាចនាំចេញនូវផលិតផលសត្វចូលទៅក្នុងទីផ្សារអាស៊ានបាន នៅពេលកម្ពុជា បានបំពេញតាមទិសដៅសមាហរណកម្ម អាស៊ានឆ្នាំ២០១៥ ដែលតម្រូវឲ្យប្រទេសក្នុងតំបន់អាស៊ាននីមួយៗ មានច្បាប់ស្តីពីការបង្កើត និងការគ្រប់គ្រងកសិដ្ឋានចិញ្ចឹមសត្វ និងលិខិតបញ្ជាក់ការអនុវត្តល្អប្រសើរនៃកសិដ្ឋានចិញ្ចឹមសត្វ ( Good Animal Husbandry Practice) ទើបអាចធ្វើអាជីវ-

កម្មនាំចេញសាច់សត្វ ឬសត្វទៅលក់នៅក្នុងតំបន់អាស៊ានបាន និងពិសេសការចូលរួមអនុវត្តយុទ្ធ-សាស្ត្រចតុកោណដំណាក់កាលទី៣របស់រាជរដ្ឋាភិបាលដែលនៅក្នុងចតុកោណទី១ បានកំណត់អំពីការលើកស្ទួយវិស័យកសិកម្ម។

**ការពិគ្រោះយោបល់៖** ក្រោយពីបានជួបពិគ្រោះយោបល់ជាមួយសមត្ថកិច្ចសាធារណៈ តំណាងនៃផ្នែកឯកជន និងជាមួយប្រជាពលរដ្ឋរួចមក ក្រុមការងារ បានធ្វើសេចក្តីសន្និដ្ឋានលើការ ពិគ្រោះយោបល់ដូចខាងក្រោម៖

១- គាំទ្រលើការរៀបចំសេចក្តីព្រាងប្រកាសស្តីពីការបង្កើត និងការគ្រប់គ្រងកសិដ្ឋានចិញ្ចឹមសត្វ។

២-ស្នើក្រសួងពិចារណានូវករណីនៃការចុះបញ្ជីកសិដ្ឋាន ពុំគួរចុះបញ្ជីនៅថ្នាក់ជាតិទាំងអស់នោះទេ រីឯសុពលភាពលិខិតអនុញ្ញាតមានរយៈពេល៥ឆ្នាំក្នុងសេចក្តីព្រាងប្រកាសនៅត្រង់ប្រការ៦ គួរកាត់បន្ថយរយៈពេល ដើម្បីងាយស្រួលណែនាំដល់ម្ចាស់កសិដ្ឋាន។

៣-បច្ចេកទេសនៃការចិញ្ចឹមសត្វរបស់កសិករ ឬអាជីវករចិញ្ចឹមសត្វនៅមានកម្រិត គួររាជរដ្ឋាភិបាល ( ក្រសួងកសិកម្ម រុក្ខាប្រមាញ់និងនេសាទ ) ជួយផ្នែកបច្ចេកទេស តាមរយៈការផ្តល់នូវវគ្គបណ្តុះ-បណ្តាលស្តីពីបច្ចេកទេសនៃការចិញ្ចឹមសត្វ។

៤-ការគ្រប់គ្រងលាមកនិងកាកសំណល់សត្វមិនបានត្រឹមត្រូវតាមបទដ្ឋានបច្ចេកទេស បានបង្កជាផលប៉ះពាល់ដល់ការរស់នៅរបស់ប្រជាពលរដ្ឋ ជាក់ស្តែងតែងតែមានបណ្តឹងចំពោះក្លិនស្អុយពីកាកសំណល់និងទឹកស្អុយយពីលាមកមាន់ ឬលាមកជ្រូក។ កសិដ្ឋានខ្លះ បានស្ថិតនៅឆ្ងាយពីភូមិដ្ឋានប្រជាពលរដ្ឋ តែលាមកសត្វ និងកាកសំណល់មិនបានទុកដាក់ និងគ្រប់គ្រងតាមបទដ្ឋានបច្ចេកទេសដែលបានធ្វើឲ្យហូរចូលស្រែ ឬបឹងបួរធម្មជាតិនៅជុំវិញកសិដ្ឋាន បង្កជាផលប៉ះពាល់ដល់បរិស្ថាន ។

**សន្និដ្ឋាន៖** ផ្អែកតាមការពិគ្រោះយោបល់ ការសិក្សា និងការវិភាគអំពីផលប៉ះពាល់ដូចបានអធិប្បាយខាងលើ គេអាចសន្និដ្ឋានបានថា ជម្រើសទី២ (សេចក្តីព្រាងប្រកាសស្តីពីការបង្កើត និងការគ្រប់គ្រងកសិដ្ឋានចិញ្ចឹមសត្វ) នឹងធ្វើឲ្យកសិដ្ឋានចិញ្ចឹមសត្វនៅកម្ពុជា មានការគ្រប់គ្រងតាមបទដ្ឋានបច្ចេកទេសមួយច្បាស់លាស់ ដើម្បីធានានិងការពារសុវត្ថិភាព និងសុខភាពសាធារណៈ ពិសេសការការពារបរិស្ថាននិងការទប់ស្កាត់ការរីករាលដាលនៃជំងឺឆ្លងសត្វ ដែលជាកត្តាប៉ះពាល់ធ្ងន់ធ្ងរដល់ផលិតកម្មសត្វ និងសេដ្ឋកិច្ចសង្គម។ លើសពីនេះ វាក៏នឹងផ្តល់ប្រយោជន៍ដល់សង្គមជាតិមានជាអាទិ៍ចូលរួមក្នុងកំណើនសេដ្ឋកិច្ចជាតិ តាមរយៈការបង្កើនសមត្ថភាពប្រកួតប្រជែង នៃការចិញ្ចឹមសត្វក្នុងស្រុក ដើម្បីជំរុញផលិតកម្មសត្វសម្រាប់បំពេញតម្រូវការផ្គត់ផ្គង់ក្នុងស្រុកនិងឈានទៅដល់ការនាំចេញនាពេលអនាគត។ ម្យ៉ាងវិញទៀត បញ្ញត្តិកម្មនេះ ពិតជាធ្វើឲ្យវិស័យចិញ្ចឹមសត្វនៅកម្ពុជាអាចពង្រីកខ្លួនពីការចិញ្ចឹមទ្រង់ទ្រាយតូចៗដែលគ្មានការគ្រប់គ្រង ប្រមូលផ្តុំទៅជាការចិញ្ចឹមតាមលក្ខណៈពាក់កណ្តាលឧស្សាហកម្ម និងឧស្សាហកម្ម ដើម្បីជួយបំពេញតម្រូវការសាច់សត្វក្នុងប្រទេសដែលកំពុងកើនឡើងខ្ពស់ហួសពីការផ្គត់ផ្គង់ ហើយស្របនឹងបរិបទនៃក្របខ័ណ្ឌនៃអង្គការពាណិជ្ជកម្មពិភពលោក (WTO) អង្គការសុខភាពសត្វពិភពលោក (OIE) និងការធ្វើសមាហរណកម្មកម្ពុជាជាមួយអាស៊ាន ( ASEAN ) និងជាមួយបណ្តាប្រទេសក្នុងតំបន់ និងផ្អែកតាមទិដ្ឋភាពជាក់ស្តែងដែលច្បាប់ស្តីពីសុខភាពសត្វ និងផលិតកម្មសត្វ នៅមិនទាន់ត្រូវបានអនុម័តដាក់ឲ្យអនុវត្តនៅឡើយនោះ សេចក្តីព្រាងប្រកាសនេះពិតជាមានសារសំខាន់ និងជាកាលៈទេសៈមួយសមស្របសម្រាប់ក្រសួងរៀបចំដំណើរការសម្រេចនិងដាក់ឲ្យអនុវត្ត។ ទន្ទឹមនឹងនេះ ដើម្បីឲ្យសេចក្តីព្រាងប្រកាស នេះកាន់តែមានខ្លឹមសារគ្រប់

ជ្រុងជ្រោយ គួរក្រសួងពិនិត្យ ពិចារណា និងកែសម្រួលនូវខ្លឹមសារមួយចំនួននៃសេចក្តីព្រាងប្រកាស មានជាអាទិ៍ ការចុះបញ្ជីកសិដ្ឋាន សុពលភាពលិខិតអនុញ្ញាត លក្ខខណ្ឌតម្រូវ...។

**ការអនុវត្ត តាមដាន និងការវាយតម្លៃ៖** ក្រោយពេលប្រកាសស្តីពីការបង្កើត និងការគ្រប់គ្រងកសិដ្ឋានចិញ្ចឹមសត្វត្រូវបានក្រសួងប្រកាសដាក់ឲ្យអនុវត្តជាផ្លូវការ នោះវិធានការជំរុញការអនុវត្តច្បាប់ត្រូវអនុវត្តតាមដំណាក់កាលសំខាន់ដូចតទៅ៖

ក-ដំណាក់កាលផ្សព្វផ្សាយប្រកាស: សមត្ថកិច្ចនាយកដ្ឋានផលិតកម្មនិងបសុព្យាបាលនៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ នឹងបង្កើតកម្មវិធីផ្សព្វផ្សាយខ្លឹមសារប្រកាស។ នាយកដ្ឋានផលិតកម្មនិងបសុព្យាបាល ត្រូវចុះសហការជាមួយមន្ទីរកសិកម្មរាជធានីខេត្តនិងអាជ្ញាធររដ្ឋបាលថ្នាក់ក្រោមជាតិ ផ្សព្វផ្សាយឲ្យបានទូលំទូលាយដល់អ្នកចិញ្ចឹមសត្វនៅក្នុងរយៈពេល០៣ខែ តាមកម្មវិធីផ្សព្វផ្សាយដែលបានរៀបចំឡើង។

ខ-ដំណាក់កាលតាមដានការអនុវត្តច្បាប់: ក្នុងអំឡុងពេលនៃការប្រតិបត្តិបញ្ញត្តិកម្មនេះ ដើម្បីលើកកម្ពស់តម្លាភាព និងអភិបាលកិច្ចល្អ ត្រូវឲ្យមានការចុះធ្វើអធិការកិច្ចបួនដងក្នុងមួយឆ្នាំ ក្នុងនោះមានការចុះពិនិត្យតាមដានដោយមន្ត្រីមានសមត្ថកិច្ចថ្នាក់រាជធានីខេត្តចំនួនបីដង និងការធ្វើអធិការកិច្ចដោយថ្នាក់ក្រសួងនៅក្នុងម្រម៉ាំឆ្នាំនីមួយៗនៅតាមកសិដ្ឋានចិញ្ចឹមសត្វ។

គ-ដំណាក់កាលសិក្សានិងវាយតម្លៃការអនុវត្តច្បាប់: បញ្ញត្តិកម្មនេះ នឹងត្រូវត្រួតពិនិត្យឡើងវិញក្នុងអំឡុងពេល៥ឆ្នាំ*ម្តង* តាមរយៈការបង្កើតយន្តការសិក្សានិងវាយតម្លៃការអនុវត្តដោយផ្តោតជាសំខាន់លើព័ត៌មានត្រឡប់ពីធុរកិច្ច ( ម្ចាស់កសិដ្ឋាន ) ការវិវត្តន៍នៃសេដ្ឋកិច្ច និងនយោបាយរបស់រាជរដ្ឋាភិបាល។

# របាយការណ៍ស្តីពីការវាយតម្លៃពេញលេញលើសេចក្តីព្រាងប្រកាស ស្តីពីការបង្កើតនិងការគ្រប់គ្រងកសិដ្ឋានចិញ្ចឹមសត្វ

## ១.ការកំណត់បញ្ហា

### ១.១សុខភាព និងសុវត្ថិភាពសាធារណៈ

សុវត្ថិភាពចំណីអាហារជាកត្តាចម្បងដល់សុខភាពមនុស្ស ដែលចាំបាច់ត្រូវមានការត្រួតពិនិត្យពីផលិតផលដំបូងរហូតដល់ការកែច្នៃ។ កត្តានេះ និយាយដោយឡែកនៅកម្ពុជា ផលិតផលសាច់សត្វនៅមិនទាន់ធានា នូវសុវត្ថិភាពដល់ការបរិភោគនៅឡើយទេ ដោយសារសាច់សត្វដែលកំពុងផ្គត់ផ្គង់នៅលើទីផ្សារមិនមានប្រភពចេញពីកសិដ្ឋានចិញ្ចឹមសត្វ ដែលមានវិធានបសុព្យាបាលនិងបទដ្ឋានបច្ចេកទេសគ្រប់គ្រាន់។កន្លែងចិញ្ចឹមសត្វភាគច្រើនមិនមានលិខិតអនុញ្ញាត និងគ្មានបទដ្ឋានបច្ចេកទេសនៃការចិញ្ចឹមត្រឹមត្រូវ។ ម្យ៉ាងទៀត សត្វមានជំងឺដូចជា ជំងឺប៉េះគោ-ក្របី ជំងឺរលាកស្រោមសួតគោ-ក្របី ជំងឺប៉េះជ្រូក ជំងឺឈាមខ្មៅ ជំងឺឆ្កួត ជំងឺបូសខ្យល់ ជំងឺសាទឹក ជំងឺចុងអង្គរ និងជំងឺផ្តាសាយបក្សីជាដើម ត្រូវបានគេដឹកជញ្ជូន និងធ្វើពាណិជ្ជកម្មនៅលើទីផ្សារ។ ជំងឺទាំងនេះ មានលក្ខណៈកាចសាហាវ និងឆ្លងរាតត្បាតឆាប់រហ័សបំផុតគ្មានព្រំដែនកំណត់ជាក់លាក់និងធ្វើឲ្យមានផលវិបាក ខ្លាំងដល់សុខភាពសាធារណៈនិងសេដ្ឋកិច្ចសង្គម។ ជាក់ស្តែង យោងតាមរបាយការណ៍របស់អង្គការសុខភាពពិភពលោកឆ្នាំ២០១៣ ជំងឺផ្តាសាយបក្សីបានបណ្តាលឲ្យមនុស្សស្លាប់បាត់បង់ជីវិតអស់ចំនួន ៣៧នាក់ ដោយឡែកប្រទេសកម្ពុជាមានប្រជាពលរដ្ឋស្លាប់ចំនួន២៩នាក់ ។

### ១.២.ការការពារបរិស្ថាន

អ្នកចិញ្ចឹមសត្វនៅប្រទេសកម្ពុជាមានទម្លាប់ចិញ្ចឹមសត្វ ដោយគ្មានការគ្រប់គ្រងដូចជា លែងចោលពាសវាលពាសកាល រីឯការចិញ្ចឹមសត្វខ្លះទៀតមានទ្រង់ទ្រាយជាកសិដ្ឋានដែរ តែទីតាំងនៅមិនទាន់សម-ស្រប គ្មានបទដ្ឋានបច្ចេកទេស គ្មានការត្រួតពិនិត្យពីសមត្ថកិច្ចផលិតកម្មនិងបសុព្យាបាល បណ្តាលឲ្យប៉ះពាល់បរិស្ថានដូចជាក្លិនស្អុយពីកាកសំណល់នៃការចិញ្ចឹមសត្វ និងបានបង្ករឲ្យមានសត្វរុយ និងសត្វល្អិតផ្សេងៗទៀត ការបង្ហូរទឹកកខ្វក់ សម្លេងសត្វស្រែក ការចម្លងមេរោគតាមខ្យល់។ល។ ធ្វើឲ្យប៉ះពាល់ដល់អ្នករស់នៅជិតខាង (ការចុះសម្ភាសន៍ផ្ទាល់ជាមួយសមត្ថកិច្ចផលិតកម្មនិងបសុ-ព្យាបាល និងប្រជាពលរដ្ឋពាក់-ព័ន្ធ)។ ទន្ទឹមនឹងនេះដែរ តាមរយៈនៃការជួបពិគ្រោះយោបល់ជាមួយសមត្ថកិច្ចមូលដ្ឋាន និងមន្ត្រីជំនាញបសុព្យាបាលនៅខេត្តកំពង់ស្ពឺ កំពង់ឆ្នាំងព្រៃវែង កំពង់ចាម និងខេត្តរតនគិរីបានឲ្យដឹងថា មានប្រជាពលរដ្ឋដែលបានចូលរួមក្នុងវេទិកាសាធារណៈជាច្រើន បានសំណូមពរដល់អាជ្ញាធរមានសមត្ថកិច្ចឲ្យមានវិធានការដោះស្រាយចំពោះកសិដ្ឋានចិញ្ចឹមសត្វ មានបរិស្ថានមិនសមស្រប (ដូចជាមានក្លិនស្អុយ មានរុយច្រើន កាកសំណល់ បង្ហូរចូលប្រឡាយទឹកឬស្រែកសិករជាដើម) ។

### ១.៣.ការប្រកួតប្រជែង

ការចិញ្ចឹមសត្វជាលក្ខណៈគ្រួសារ និងការចិញ្ចឹម សម្រាប់ធ្វើអាជីវកម្មនៅក្នុងព្រះរាជាណា-ចក្រកម្ពុជា ត្រូវបានរដ្ឋលើកទឹកចិត្ត មិនមានការហាមប្រាមឬរឹតបន្តឹងទេ តែការចិញ្ចឹមសត្វហាក់នៅមានកម្រិតនៅឡើយ។ បរិមាណផ្គត់ផ្គង់សាច់សត្វរបស់កម្ពុជា សម្រាប់តម្រូវការហូបចុកនៅក្នុងប្រទេសនៅ

មិនទាន់គ្រប់គ្រាន់នៅឡើយ ដែលចាំបាច់តម្រូវឲ្យមានការនាំចូលសាច់សត្វ សត្វរស់ និងស៊ុតពីក្រៅប្រទេស។ ដូច្នេះ សមត្ថភាពប្រកួតប្រជែងលើការចិញ្ចឹមសត្វនៅកម្ពុជានៅទន់ខ្សោយ ដោយសារថ្លៃដើមនៃការចញ្ចឹមមានកម្រិតខ្ពស់ មិនអាចប្រកួតជាមួយសាច់សត្វដែលនាំចូលពីក្រៅប្រទេសបាន ឧទាហរណ៍ជ្រូកសាច់នាំចូលពីប្រទេសជិតខាងកម្ពុជា មានតម្លៃថោកជាងជ្រូកសាច់ ដែលបានចិញ្ចឹមនៅក្នុងស្រុក។ ករណីថ្លៃដើមនៃការចញ្ចឹមមានកម្រិតខ្ពស់ ដែលបណ្តាលមកពីកត្តាពូជ ចំណី និងកត្តាបច្ចេកទេសនៃការចិញ្ចឹមនោះ ម្យ៉ាងទៀតលំហូរនៃការនាំចូលសាច់សត្វ សត្វរស់ និងស៊ុតពីក្រៅប្រទេសបានកំពុងធ្វើឲ្យមានផលប៉ះពាល់អវិជ្ជមានដល់ការចិញ្ចឹមសត្វក្នុងស្រុក (កិច្ចសម្ភាសន៍ជាមួយសមត្ថកិច្ចផលិតកម្មនិងបសុព្យាបាលនិងអ្នកចិញ្ចឹមសត្វនៃខេត្តកំពង់ស្ពឺ ព្រៃវែង កំពង់ឆ្នាំង កំពង់ចាម និងខេត្តរតនគិរី )។

កង្វះខាតបទដ្ឋានគត្តិយុត្តពាក់ព័ន្ធនឹងការចិញ្ចឹមសត្វ ក៏ជាឧបសគ្គដល់ការវិនិយោគលើការចិញ្ចឹមសត្វផងដែរ ហើយអាចធ្វើឲ្យប្រទេសកម្ពុជាបាត់បង់សមត្ថភាពប្រកួតប្រជែងជាអន្តរជាតិលើការនាំចេញសាច់សត្វ ឬសត្វ។ តាមទិសដៅសមាហរណកម្មអាស៊ានឆ្នាំ២០១៥ ប្រទេសអាស៊ាននីមួយៗតម្រូវឲ្យមានច្បាប់ស្តីពីការបង្កើត និងការគ្រប់គ្រងកសិដ្ឋានចិញ្ចឹមសត្វនិងលិខិតបញ្ជាក់ការអនុវត្តល្អប្រសើរនៃកសិដ្ឋានចិញ្ចឹមសត្វ ( Good Animal Husbandry Practice ) ទើបអាចធ្វើអាជីវកម្មនាំចេញសាច់សត្វ ឬសត្វទៅលក់នៅក្នុងតំបន់អាស៊ានបាន (កិច្ចសម្ភាសន៍ជាមួយនឹងមន្ត្រីមានសមត្ថកិច្ច នៃនាយកដ្ឋានផលិតកម្មនិងបសុព្យាបាល)។

**១.៤.ការគ្រប់គ្រងព័ត៌មាន និងទិន្នន័យនៃការចិញ្ចឹមសត្វ**

នាយកដ្ឋានក៏ដូចជាក្រសួងកសិកម្មរុក្ខាប្រមាញ់និងនេសាទ កំពុងជួបការលំបាកលើការគ្រប់គ្រងព័ត៌-មាន និងទិន្នន័យនៃការចិញ្ចឹមសត្វ ដោយក្តាប់មិនបានពីស្ថិតិសត្វនិងស្ថានភាពជំងឺសត្វ ពិសេសការប្រមូលទិន្នន័យសម្រាប់កសាងគោលនយោបាយ យុទ្ធសាស្ត្រ និងផែនការរបស់ក្រសួងក្នុងវិស័យសត្វ។ ទន្ទឹមនឹងនេះ ព័ត៌មានពាក់ព័ន្ធនឹងជំងឺឆ្លងសត្វ ក៏មានការប្រឈមក្នុងគ្រប់គ្រង ដោយសារការចិញ្ចឹមពុំមានលក្ខណៈប្រមូលផ្តុំ ដោយពុំមានច្បាប់ទម្លាប់ត្រឹមត្រូវ ។

**១.៥.កង្វះលិខិតបទដ្ឋានគតិយុត្តសម្រាប់គ្រប់គ្រងការចិញ្ចឹមសត្វ**

ផលិតកម្មសត្វនិងសុខភាពសត្វ ជាអនុវិស័យមួយយ៉ាងសំខាន់នៃវិស័យកសិកម្មក្នុងការចូលរួមចំណែកនៅក្នុងកំណើនសេដ្ឋកិច្ចជាតិ។ អនុវិស័យនេះ បានដើរតួនាទីក្នុងការផ្គត់ផ្គង់សេចក្តីត្រូវការសាច់សត្វ និងសត្វក្នុងស្រុក និងក្នុងតំបន់ ដោយបានចូលរួមយ៉ាងសកម្មក្នុងការកាត់បន្ថយភាពក្រីក្រ និងធ្វើឲ្យជីវភាពរបស់ប្រជាពលរដ្ឋមានភាពធូរធារស្របតាមគោលនយោបាយកាត់បន្ថយភាពក្រីក្ររបស់រាជរដ្ឋាភិបាល។ យ៉ាងណាមិញលិខិតបតដ្ឋានគតិយុត្ត សម្រាប់គ្រប់គ្រងអនុវិស័យនេះ នៅមាន ភាពខ្វះចន្លោះនៅឡើយ៖

១.៥.១.អនុក្រឹត្យលេខ១៦អនក្រ.បក ស្តីពីការត្រួតពិនិត្យអនាម័យសត្វ និងផលិតផលមានដើមកំណើតពីសត្វ: ស្មារតីអនុក្រឹត្យនេះ ផ្តោតនិងគ្រប់ដណ្តប់ទៅលើតែអនាម័យសត្វ ដោយធ្វើការទប់ស្កាត់ការរីករាលឆ្លងជំងឺសត្វ ការពារសុខភាពសត្វនិងការពារសុខភាពសាធារណៈ ដោយអនុវត្តវិធានបសុពេទ្យលើរាល់ការនាំចូល នាំចេញ ឆ្លងកាត់ និងដឹកជញ្ជូនក្នុងប្រទេស។ ប៉ុន្តែអនុក្រឹត្យលេខ១៦នេះ មិនបានគ្រប់គ្រងទៅលើការងារផលិតកម្មសត្វនោះទេ ។

១.៥.២.អនុក្រឹត្យលេខ១០៨ អនក្រ.បក ស្តីពីការគ្រប់គ្រងសត្តឃាតដ្ឋាន ការត្រួតពិនិត្យអនាម័យសត្វ សាច់ និងផលិតផលសត្វៈ អនុក្រឹត្យនេះ កំណត់អំពីការគ្រប់គ្រងសត្តឃាតដ្ឋាន សកម្មភាពអាជីវកម្មពិឃាតសត្វ ការត្រួតពិនិត្យអនាម័យសត្វ សាច់ និងផលិតផលសត្វនៅតាមសត្តឃាតដ្ឋាននិងកន្លែងលក់ក្នុងគោលបំណងទប់ស្កាត់ការរីករាលដាលជំងឺសត្វ ការពារសុខភាពសត្វ ធានាគុណភាពផលិតផល និងការពារសុខភាពសាធារណៈ។ រីឯផលិតកម្មសត្វវិញ អនុក្រឹត្យនេះ ក៏មិនគ្រប់គ្រងដែរ ដោយផ្តោតទៅលើតែការគ្រប់-គ្រងផ្នែកអនាម័យប៉ុណ្ណោះ។

១.៥.៣.អនុក្រឹត្យលេខ២៦ អនក្រ.បក ស្តីពីការបង្កើតនិងការគ្រប់គ្រងភ្នាក់ងារសុខភាពសត្វភូមិ។

១.៥.៤.សេចក្តីព្រាងច្បាប់ស្តីពីសុខភាពសត្វនិងផលិតកម្មសត្វៈ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បញ្ជូនដល់ទីស្តីការគណៈរដ្ឋមន្ត្រីដើម្បីសុំការសម្រេចពីប្រមុខរាជរដ្ឋាភិបាល។ បច្ចុប្បន្នសេចក្តីព្រាងច្បាប់នេះ នៅមិនទាន់ត្រូវបានអនុម័តដាក់ឲ្យអនុវត្តនៅឡើយ។

ក្រៅពីអនុក្រឹត្យទាំងបីខាងលើ ក្រសួងបានចេញប្រកាសចំនួន១៩ ក្នុងនោះមានប្រកាសចំនួន០៨ បានរៀបចំឡើងផ្អែកតាមស្មារតីអនុក្រឹត្យលេខ១៦ អនក្រ.បក ស្តីពីការត្រួតពិនិត្យអនាម័យសត្វ និងផលិតផលមានដើមកំណើតពីសត្វ ចំនួន០៧ស្ថិតក្រោមស្មារតីអនុក្រឹត្យលេខ១០៨ អនក្រ.បក ស្តីពីការគ្រប់គ្រងសត្តឃាតដ្ឋាន ការត្រួតពិនិត្យអនាម័យសត្វ សាច់ និងផលិតផលសត្វចំនួន០២ ស្ថិតក្រោមស្មារតីអនុក្រឹត្យលេខ២៦ អនក្រ.បក ស្តីពីការបង្កើតនិងការគ្រប់គ្រងភ្នាក់ងារសុខភាពសត្វ ភូមិ និងប្រកាសចំនួន០២គឺប្រកាសលេខ៣៦៨ប្រក.កសកចុះថ្ងៃទី១៦ ខែសីហា ឆ្នាំ២០០១ស្តីពីការបង្កើតគណៈកម្មាធិការចុះបញ្ជិកា និងការផ្តល់លិខិតអនុញ្ញាតសេវាកម្មផលិតកម្ម និងបសុព្យាបាល និងប្រកាសរួមលេខ១០១៣ សហវ.ប្រក ចុះថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០១២ ស្តីពីការផ្តល់សេវាសាធារណៈរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។ថ្វីបើអនុវិស័យនេះ មានលិខិតបទដ្ឋានជាអនុក្រឹត្យ និងប្រកាសជាច្រើនសម្រាប់គ្រប់គ្រងក៏ដោយ តែលិខិតបទដ្ឋានទាំងនោះ គ្រប់គ្រងបានតែទៅលើផ្នែកអនាម័យសត្វនៅពេលដឹកជញ្ជូនប៉ុណ្ណោះ រីឯផ្នែកផលិតកម្ម ឬការចិញ្ចឹមសត្វ នៅមិនទាន់មានអត្ថបទច្បាប់ណាមួយច្បាស់លាស់នៅឡើយទេ។ ទន្ទឹមនឹងនេះ ក្រសួងកសិកម្ម រុក្ខាប្រមាញ់និងនេសាទបានបង្កើតបានសេចក្តីព្រាងច្បាប់ស្តីពីសុខភាពសត្វនិង ផលិតកម្មសត្វ ហើយបានបញ្ជូនសេចក្តីព្រាងនេះទៅរាជរដ្ឋាភិបាលរួចហើយ តែមកដល់បច្ចុប្បន្ន ច្បាប់នេះក៏នៅមិនទាន់ត្រូវបានអនុម័តនៅឡើយដែរ។ ទោះបីយ៉ាងណា ក៏លិខិតបទដ្ឋានទាំងនោះ នៅមិនទាន់ឆ្លើយតបនឹងតម្រូវការនៃស្ថានការអភិវឌ្ឍន៍វិស័យចិញ្ចឹមសត្វនៅឡើយទេ។ ដើម្បីតេ់ឲ្យទាន់សភាពការណ៍ក្នុងតំបន់ ពិសេសគោលដៅពាណិជ្ជកម្មនៃតំបន់អាស៊ាន បានកំពុងតម្រូវឲ្យកម្ពុជាពង្រឹង សមត្ថភាពក្នុងក្របខ័ណ្ឌច្បាប់ ទើបអាចមានសមត្ថភាពប្រកួតប្រជែងសេដ្ឋកិច្ចទាំងក្នុងតំបន់ និងទាំងនៅកម្រិតអន្តរជាតិបាន។

រួមសេចក្តីមក ការចិញ្ចឹមសត្វភាគច្រើនមានទ្រង់ទ្រាយជាលក្ខណៈគ្រួសារ រីឯការចិញ្ចឹមបែបពាក់កណ្តាលឧស្សាហកម្មនិងឧស្សាហកម្មមានចំនួនតិចតួច ដែលកម្ពុជានៅមិនទាន់អាចផ្គត់ផ្គង់សាច់សត្វសម្រាប់បំពេញតម្រូវការហូបចុកនៅក្នុងប្រទេសបាននៅឡើយ។ ដូចនេះ កម្ពុជាចាំបាច់ត្រូវនាំចូលសាច់សត្វ សត្វរស់ និងស៊ុតពីក្រៅប្រទេស ដើម្បីបំពេញតម្រូវការក្នុងស្រុក។ ទន្ទឹមនឹងនេះដែរ សមត្ថភាពប្រកួតប្រជែងលើការចិញ្ចឹមសត្វនៅកម្ពុជានៅទន់ខ្សោយ ដោយសារថ្លៃដើមនៃការចញ្ចឹមមានកម្រិតខ្ពស់ មិនអាចប្រកួតប្រជែងជាមួយសត្វ ដែលនាំចូលពីក្រៅប្រទេសបាន។ ករណីថ្លៃដើមនៃ

ការចញ្ចឹមមានតម្លៃខ្ពស់ ដែលបណ្តាលមកពីកត្តាពូជ ចំណី និងកត្តាបច្ចេកទេសនៃការចិញ្ចឹមនោះ ម្យ៉ាងទៀតលំហូរនៃការនាំចូលសាច់សត្វ សត្វរស់ និងស៊ុតពីក្រៅប្រទេស ក៏បានធ្វើឲ្យមានផលប៉ះ-ពាល់អវិជ្ជមានដល់ការចិញ្ចឹមសត្វក្នុងស្រុកផងដែរ។ ក្រៅពីកត្តាផលិតកម្មសត្វនិងកត្តាសមត្ថភាពនៃការចិញ្ចឹមនៅមានកម្រិត កម្ពុជាក៏នៅមានបញ្ហាប្រឈមលើការគ្រប់គ្រងនៃការរីករាលដាលនៃជំងឺឆ្លងផលបះពាល់បរិស្ថាន និងការគ្រប់គ្រងព័ត៌មាន និងទិន្នន័យនៃការចិញ្ចឹមសត្វ ព្រោះប្រទេសកម្ពុជាមិនទាន់មានលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងការគ្រប់គ្រងការចិញ្ចឹមសត្វនៅឡើយទេ។

## ២.គោលបំណង ភារកិច្ច និងវិសាលភាព

### ២.១. គោលបំណង

ដើម្បីបង្កើនផលិតភាពសត្វ ទប់ស្កាត់ការរីករាលដាលជំងឺសត្វ ការពារសុខភាពសត្វ សុខមាលភាពសត្វ សុខភាពសាធារណៈ និងបរិស្ថាន ។ គោលបំណងនេះ ស្របនឹងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៣ របស់រាជរដ្ឋាភិបាលនៅក្នុងចតុកោណទី១ ដែលកំណត់អំពីការលើកស្ទួយវិស័យកសិកម្ម ក្នុងនោះមាននិយាយពីការលើកកម្ពស់ចលនាចិញ្ចឹមសត្វ ឲ្យកាន់តែទូលំទូលាយថែមទៀតតាមរយៈ៖

ក-ការជំរុញរៀបចំ និងដាក់ឲ្យអនុវត្តនូវគោលនយោបាយ និងយុទ្ធសាស្ត្រស្តីពីការលើកកម្ពស់ការចិញ្ចឹមសត្វ។

ខ-ការជំរុញការលើកកម្ពស់ការស្រាវជ្រាវ និងការអភិវឌ្ឍលើការបង្កាត់ពូជ ការគ្រប់គ្រងសុខភាពសត្វ ការផលិតចំណីសត្វ និងប្រព័ន្ធកសិដ្ឋានក្នុងវិស័យបសុសត្វ។

គ-ការជំរុញអនុម័តច្បាប់ស្តីពីសុខភាពសត្វ និងផលិតកម្មសត្វ ដើម្បីជាមូលដ្ឋានសម្រាប់រៀបចំស្ថាប័ន និងគ្រប់គ្រងវិស័យនេះ ក្នុងគោលដៅពង្រឹងការអនុវត្តស្តង់ដាអនាម័យលើផលិតផលពីសត្វ ការពង្រឹងនិងជំរុញអនុវត្តវិធានការអនាម័យសត្វ ភូតគាមអនាម័យ ដើម្បីបង្ការ ទប់ស្កាត់ និងលុបបំបាត់ការរាលដាលជំងឺសត្វ ក៏ដូចជាដើម្បីការពារសុខភាពសាធារណៈ។

ឃ-ការជំរុញលើកទឹកចិត្តការវិនិយោគលើការផលិតចំណីសត្វក្នុងទ្រង់ទ្រាយមធ្យមនិងធំ ដើម្បីគាំទ្រដល់ចលនាចិញ្ចឹមសត្វ រួមជាមួយនឹងការលើកកម្ពស់ប្រព័ន្ធផ្តល់សេវាបច្ចេកទេស ពូជ ឥណទាន និងការរកទីផ្សារជូនកសិករ ការលើកទឹកចិត្តការវិនិយោគឯកជនក្នុងការកែច្នៃផលិតផលបសុសត្វ និងការបង្កើតសត្តឃាតដ្ឋានទំនើប ព្រមទាំងការសម្របសម្រួលពាណិជ្ជកម្មលើបសុសត្វ និងផលិតផលមានដើមកំណើតពីសត្វ។

### ២.២. ភារកិច្ច និងវិសាលភាព

ប្រកាសនេះ ចែងពីការគ្រប់គ្រងកសិដ្ឋានចិញ្ចឹមសត្វ ដើម្បីទប់ស្កាត់ការរីករាលដាលជំងឺឆ្លងសត្វ ការពារសុខភាពសត្វ សុខភាពសាធារណៈ និងការការពារបរិស្ថាន។ នីតិបុគ្គល ឬរូបវន្តបុគ្គលដែលមានបំណងប្រកបអាជីវកម្មចិញ្ចឹមសត្វមានភារកិច្ច ដូចខាងក្រោម៖

- ស្នើសុំលិខិតអនុញ្ញាតបង្កើតកសិដ្ឋាន និងសុំចុះបញ្ជីកសិដ្ឋាន
- ការសាងសង់ត្រូវគោរពតាមបទដ្ឋានបច្ចេកទេស
- ធានាការអនុវត្តវិធានបសុព្យាបាល និងបទដ្ឋានបច្ចេកទេសគ្រប់គ្រាន់សម្រាប់ការចិញ្ចឹមសត្វ។

ប្រកាសនេះមានវិសាលភាពអនុវត្តចំពោះកសិដ្ឋានចិញ្ចឹមសត្វ ខ្នាតធំ ខ្នាតមធ្យម និងខ្នាតតូច។

## ៣.ជម្រើស

តាមវិធីសាស្ត្រRIA មានជម្រើសចំនួន២ ត្រូវបានយកមកធ្វើការសិក្សានិងវាយតម្លៃពេញលេញអំពីផលប៉ះពាល់លើសេចក្តីព្រាងប្រកាសដែលបានរៀបចំឡើង ដើម្បីប្រៀបធៀបរកឲ្យឃើញអំពីផលប៉ះពាល់។

**៣.១.ជម្រើសទី១៖** រក្សាស្ថានភាពដើម ដោយបន្តពង្រឹងការអនុវត្តលិខិតបទដ្ឋានដែលមានស្រាប់។ តាមរបាយការណ៍បូកសរុបការងារវិស័យកសិកម្មឆ្នាំ២០១៤ ស្ថិតិកសិដ្ឋានចិញ្ចឹមសត្វមានចំនួនប្រមាណ១.៣១២ កន្លែង ក្នុងនោះកសិដ្ឋានចិញ្ចឹមសត្វដែលមានច្បាប់អនុញ្ញាតមានចំនួន៩៩កន្លែង រីឯកសិដ្ឋានចិញ្ចឹមសត្វប្រមាណ១.២១៣កន្លែងទៀត មិនមានច្បាប់អនុញ្ញាតទេ។ ចំពោះកសិដ្ឋានដែលមានច្បាប់អនុញ្ញាតពីអាជ្ញាធរមានសមត្ថកិច្ច នៅមិនទាន់អនុវត្តបានត្រឹមត្រូវតាមបទដ្ឋានបច្ចេកទេសទេ ដោយសារមិនទាន់មានលិខិតបទដ្ឋានគតិយុត្តណាមួយចែងអំពីលក្ខខណ្ឌតម្រូវនៃបទដ្ឋានបច្ចេកទេសក្នុងការចិញ្ចឹមសត្វនៅឡើយ។ ម្យ៉ាងទៀត ការចិញ្ចឹមសត្វបច្ចុប្បន្ន ក៏មិនទាន់ត្រូវបានលើកម្ពស់ការគ្រប់គ្រងឲ្យបានត្រឹមត្រូវតាមច្បាប់ទម្លាប់នៅឡើយ គឺទោះអ្នកប្រកបរបរចិញ្ចឹមសត្វចង់សុំ ឬមិនសុំច្បាប់ក៏អាចចិញ្ចឹមសត្វបាន។ អ្នកប្រកបរបរចិញ្ចឹមសត្វមានច្បាប់ មានភាពងាយស្រួលបន្តិចជាងអ្នកចិញ្ចឹមគ្មានច្បាប់ ត្រង់ការសុំវិញ្ញាបនប័ត្រត្រួតពិនិត្យអនាម័យសត្វ នៅពេលដែលត្រូវដឹកជញ្ជូនសត្វទៅលក់នៅទីផ្សារប៉ុណ្ណោះ។ សកម្មភាពចិញ្ចឹមសត្វបច្ចុប្បន្ន ដែលអនុវត្តតាមលិខិតបទដ្ឋានដែលមានស្រាប់ បានបណ្តាលឲ្យមានផលប៉ះពាល់អវិជ្ជមានដូចជា៖

- បរិស្ថាន និងការរីករាលដាលនៃជំងឺឆ្លងពីសត្វទៅសត្វនិងពីសត្វទៅមនុស្សរងហានិភ័យខ្ពស់
- ផលិតកម្មសត្វមិនត្រូវបានលើកកម្ពស់ ដែលធ្វើឲ្យកម្ពុជាប្រឈមនឹងការនាំចូលសាច់សត្វពីបរទេស ដើម្បីបំពេញតម្រូការក្នុងស្រុក
- សមត្ថភាពប្រកួតប្រជែងមានកម្រិតទាប ដែលអាចជាឧបសគ្គក្នុងដំណើរការសមាហរណកម្មអាស៊ាន
- ស្ថិតិ និងបរិមាណសត្វ ក្តាប់មិនបាន
- ការបង់ចំណូលពីការចិញ្ចឹមសត្វ ទៅក្នុងថវិកាជាតិមិនច្បាស់លាស់ ។

**៣.២.ជម្រើសទី២៖** រៀបចំសេចក្តីព្រាងប្រកាសស្តីពីការបង្កើតនិងការគ្រប់គ្រងកសិដ្ឋានចិញ្ចឹមសត្វ។ ប្រកាសនេះ មានគោលបំណងបង្កើនផលិតភាពសត្វ ទប់ស្កាត់និងលុបបំបាត់ជំងឺឆ្លងសត្វ ការពារសុខភាពសត្វ សុខភាពសាធារណៈ និងបរិស្ថាន។ លិខិតបទដ្ឋានមានស្រាប់ក្នុងវិស័យផលិតកម្ម និងបសុព្យាបាល នៅមិនទាន់អាចដោះស្រាយផលប៉ះពាល់អវិជ្ជមានមានជាអាទិ៍ ផលិតកម្មសត្វមិនទាន់ត្រូវបានលើកកម្ពស់ដែលធ្វើឲ្យកម្ពុជាមិនអាចផ្គត់ផ្គង់បំពេញតម្រូវការសាច់សត្វ ក្នុងស្រុក បរិស្ថាន និងការរីករាលដាលនៃជំងឺឆ្លងពីសត្វទៅសត្វ និងពីសត្វទៅមនុស្សមានហានិភ័យខ្ពស់ សមត្ថ-ភាពប្រកួតប្រជែងមានកម្រិតទាប ដែលអាចជាឧបសគ្គក្នុងដំណើរការសមាហរណកម្មអាស៊ាន ស្ថិតិនិងបរិមាណសត្វនៅក្តាប់មិនបាន ការបង់ចំណូលពីការចិញ្ចឹមសត្វទៅក្នុងថវិកាជាតិក៏នៅមិនទាន់អាចគ្រប់គ្រងបាន ។ ដូចនេះ ការរៀបចំបញ្ញត្តិកម្មនេះឡើង វានឹងផ្តល់ប្រយោជន៍ជាច្រើនក្នុងការជួយជម្រុញនិងលើកកម្ពស់ការចិញ្ចឹមតាមបែបពាក់កណ្តាលឧស្សាហកម្ម និងឧស្សាហកម្មដែលមានបទដ្ឋាន-បច្ចេកទេសនៃការចិញ្ចឹមត្រឹមត្រូវ ព្រមទាំងអាចដោះស្រាយរាល់ផលប៉ះ-ពាល់អវិជ្ជមាននៃ បរិស្ថាននិងការរីករាលដាលនៃជំងឺឆ្លងសត្វគ្រប់ប្រភេទនាពេលអនាគត។

## ៤.ការវិភាគផលប៉ះពាល់

### ៤.១.ជម្រើសទី១៖ រក្សាស្ថានភាពដើម ដោយពង្រឹងការអនុវត្តលិខិតបទដ្ឋានដែលមានស្រាប់

#### ៤.១.១.បន្ទុកចំណាយលើធុរកិច្ច

ទោះបីមិនទាន់មានលិខិតបទដ្ឋានណាមួយច្បាស់លាស់តម្រូវឲ្យរូបវន្ត ឬនីតិបុគ្គល ដែលមានបំណងប្រកបមុខរបរចិញ្ចឹមសត្វបច្ចុប្បន្នសុំច្បាប់អនុញ្ញាតក៏ដោយ តែបច្ចុប្បន្នមានអាជីវករចំនួន៩៩រូប បានបើកកសិដ្ឋានចិញ្ចឹមសត្វដែលមានច្បាប់អនុញ្ញាតចេញដោយអាជ្ញាធរមានសមត្ថកិច្ច ក្រៅពីនេះ មានកសិដ្ឋានចំនួន១.២១៣មិនទាន់មានច្បាប់អនុញ្ញាតទេ។កសិដ្ឋានដែលមានច្បាប់ បានចំណាយលើការសុំលិខិតអនុញ្ញាតក្នុងនោះ កសិដ្ឋានខ្នាតធំ « ប្រភេទ ក »មួយ ត្រូវចំណាយ២០០ដុល្លារ និងខ្នាតមធ្យម« ប្រភេទ ខ» ចំណាយអស់១០០ដុល្លារ ដែលកសិដ្ឋានទាំងពីរប្រភេទនេះ មានសុពលភាពរហូតដល់ទៅ៥ឆ្នាំ បើគិតជាមធ្យមកសិដ្ឋានមួយ ចំណាយត្រឹមតែ៣០ដុល្លារក្នុងមួយឆ្នាំ វាគឺជាចំណាយដ៏តិចតួច។ ក្រៅពីចំណាយរដ្ឋបាល ធុរកិច្ចក៏ត្រូវចំណាយលើការសាងសង់មិនរៀបរយ(មិនតាមបទដ្ឋានបច្ចេកទេស) និងចំណាយលើបន្ទុកបុគ្គលិក ជាមធ្យមក្នុង១កសិដ្ឋានអស់ប្រមាណ១៨.២០០ដុល្លារដែលជាចំណាយមួយទាប។ ជារួម ជម្រើសទី១នេះ ធុរកិច្ចមានបន្ទុកចំណាយ មិនគួរឲ្យកត់សម្គាល់នោះទេ។

#### ៤.១.២.បន្ទុកចំណាយលើរដ្ឋាភិបាល

ដើម្បីជំរុញផលិតកម្មសត្វ និងទប់ស្កាត់ការរីករាលដាលនៃឆ្លងសត្វ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ (នាយកដ្ឋានផលិតកម្ម និងបសុព្យាបាល) បានខិតខំពង្រឹងការអនុវត្តលិខិតបទដ្ឋានគតិយុត្ត ដែលមានស្រាប់ តាមរយៈសកម្មភាពផ្សព្វផ្សាយ និងការចុះតាមដានការអនុវត្តច្បាប់នៅតាមរាជធានី ខេត្តប្រចាំឆ្នាំ។ សកម្មភាពផ្សព្វផ្សាយ និងការចុះតាមដានការអនុវត្តច្បាប់នៅតាមរាជធានីខេត្តនេះ រដ្ឋាភិបាលបានចំណាយថវិកាអស់ចំនួនប្រមាណ៥៣.៦១៩ដុល្លារ ដែលក្នុងមួយខេត្ត ឬរាជធានី មានបន្ទុកចំណាយត្រឹមតែប្រមាណ២.១៩៥ដុល្លារប៉ុណ្ណោះ ជាចំណាយមួយដ៏តិចតួចមិនគួរឲ្យកត់ សម្គាល់។

នៅក្នុងជម្រើសទី១នេះ ពាក់ព័ន្ធនឹងបន្ទុកចំណាយទាំងធុរកិច្ចនិងរដ្ឋាភិបាល ត្រូវបានរកឃើញថា មិនមានបន្ទុកចំណាយគួរឲ្យកត់សម្គាល់នោះទេ។ ថ្វីបើ ទាំងធុរកិច្ចនិងរដ្ឋាភិបាល មានបន្ទុកចំណាយទាបក៏ពិតមែន តែគេពិនិត្យឃើញនូវបញ្ហាប្រឈម និងផលប៉ះពាល់អវិជ្ជមានដល់សង្គមដូចតទៅ៖

- បរិស្ថាន និងការរីករាលដាលនៃជំងឺឆ្លងពីសត្វទៅសត្វនិងពីសត្វទៅមនុស្សរងហានិភ័យខ្ពស់
- ផលិតកម្មសត្វមិនត្រូវបានលើកកម្ពស់ ដែលធ្វើឲ្យកម្ពុជាប្រឈមនឹងការនាំចូលសាច់សត្វពីបរទេស ដើម្បីបំពេញតម្រូវការក្នុងស្រុក
- សមត្ថភាពប្រកួតប្រជែងមានកម្រិតទាប ដែលអាចជាឧបសគ្គក្នុងដំណើរការសមាហរណកម្មអាស៊ាន

- ការចូលរួមក្នុងការបង្កើតការងារជូនប្រជាពលរដ្ឋនៅក្នុងវិស័យផលិតកម្ម និងបសុព្យាបាល នៅមានកម្រិត
- លិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងវិស័យផលិតកម្មនិងបសុព្យាបាលនៅមិនទាន់ឆ្លើយតបនឹងតម្រូវការនៃស្ថានការអភិវឌ្ឍន៍វិស័យចិញ្ចឹមសត្វនៅឡើយទេ។ ជាក់ស្តែង ក្នុងវិស័យនេះ ខ្វះលិខិតបទដ្ឋានគត្តិយុត្តពាក់ព័ន្ធនឹងការចិញ្ចឹមសត្វ វាជាឧបសគ្គដល់ការវិនិយោគលើការចិញ្ចឹមសត្វផងដែរ ហើយអាចធ្វើឲ្យប្រទេសកម្ពុជាបាត់បង់សមត្ថភាពប្រកួតប្រជែងជាអន្តរជាតិលើការនាំចេញសាច់សត្វ ឬសត្វ។ តាមទិសដៅសមាហរណកម្មអាស៊ានឆ្នាំ២០១៥ ប្រទេសអាស៊ាននីមួយៗ តម្រូវឲ្យមានច្បាប់ស្តីពីការបង្កើតនិងការគ្រប់គ្រងកសិដ្ឋានចិញ្ចឹមសត្វនិងលិខិតបញ្ជាក់ការអនុវត្តល្អប្រសើរនៃកសិដ្ឋានចិញ្ចឹមសត្វ(Good Animal Husbandry Practice) ទើបអាចធ្វើអាជីវកម្មនាំចេញសាច់សត្វ ឬសត្វទៅលក់នៅក្នុងតំបន់អាស៊ានបាន។ ដូចនេះ ដើម្បីរត់ឲ្យទាន់សភាពការណ៍ក្នុងតំបន់ ពិសេសគោលដៅពាណិជ្ជកម្មនៃតំបន់អាស៊ាន បានកំពុងតម្រូវឲ្យកម្ពុជាពង្រឹងសមត្ថភាពក្នុងក្របខ័ណ្ឌច្បាប់ ទើបអាចមានសមត្ថភាពប្រកួតប្រជែងសេដ្ឋកិច្ចទាំងក្នុងតំបន់ និងទាំងនៅកម្រិតអន្តរជាតិបាន
- ការបំពេញតួនាទីរបស់សមត្ថកិច្ចផលិតកម្ម និងបសុព្យាបាលនៅតាមកសិដ្ឋានខ្វះកិច្ចសហការពីម្ចាស់កសិដ្ឋាន
- លំបាកដល់ការសុំការត្រួតពិនិត្យអនាម័យសត្វ ក្នុងពេលធុរកិច្ចត្រូវដឹកជញ្ជូនសត្វទៅលក់នៅលើទីផ្សារក្នុងប្រទេសនិងទៅក្រៅប្រទេស
- អ្នកវិនិយោគដែលមានច្បាប់អនុញ្ញាតលើការចិញ្ចឹមសត្វ នឹងរងនូវផលប៉ះពាល់ពីការរីករាលដាលនៃជំងឺឆ្លងសត្វ ដែលផ្ទុះចេញពីកសិដ្ឋានភាគច្រើនមិនមានច្បាប់និងគ្មានបទដ្ឋានបច្ចេកទេសនៃការចិញ្ចឹមត្រឹមត្រូវ
- ស្ថិតិ និងបរិមាណសត្វ ក្តាប់មិនបាន
- ការបង់ចំណូលពីការចិញ្ចឹមសត្វ ទៅក្នុងថវិកាជាតិមិនច្បាស់លាស់ ។

**៤.២.៥ជម្រើសទី២៖ រៀបចំសេចក្តីព្រាងប្រកាសស្តីពីការបង្កើតនិងការគ្រប់គ្រងកសិដ្ឋានចិញ្ចឹមសត្វ:**

ប្រកាសនេះ រៀបចំឡើងដោយក្រុមការងាររបស់នាយកដ្ឋានផលិតកម្មនិងបសុព្យាបាល ដើម្បីដាក់សុំការពិនិត្យនិងសម្រេចពីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។ សេចក្តីព្រាងប្រកាសស្តីពីការបង្កើត និងការគ្រប់គ្រងកសិដ្ឋានចិញ្ចឹមមានចំនួន១៥ប្រការ ដោយតម្រូវឲ្យរូបវន្ត ឬនីតិបុគ្គលដែលមានបំណងប្រកបមុខរបរបង្កើតកសិដ្ឋានចិញ្ចឹមសត្វ ត្រូវសុំលិខិតអនុញ្ញាត។ កសិដ្ឋានចិញ្ចឹមសត្វ ត្រូវបានបែងចែកជាបីប្រភេទ គឺខ្នាតធំ មធ្យម និងខ្នាតតូច ហើយម្ចាស់កសិដ្ឋានត្រូវបំពេញតាមលក្ខខ័ណ្ឌតម្រូវដូចមានចែងនៅក្នុងប្រការ៣, ៦, ៧, និងប្រការ១១នៃប្រកាសនេះ ដូចខាងក្រោម៖

-មានទីតាំងនៅកន្លែងសមស្របដែលនៅឆ្ងាយពីទីប្រជុំជន ប្រភពទឹកដែលមនុស្សនិងសត្វប្រើប្រាស់ជាប្រក្រតី និងត្រូវសាងសង់តាមបទដ្ឋានបច្ចេកទេស

-មានរបងព័ទ្ធជុំវិញ និងមានពេងយាម

-សាងសង់អាងសម្រាប់ធ្វើជីវសុវត្ថិភាពសម្លាប់មេរោគនៅច្រកចេញ-ចូល

-មានចំណតយានជំនិះគ្រប់ប្រភេទ

-ត្រូវមានចម្ងាយសមស្របតាមបទដ្ឋានបច្ចេកទេសពីរោងចិញ្ចឹមមួយទៅរោងចិញ្ចឹមមួយ

-មានប្រព័ន្ធជីវសុវត្ថិភាព កន្លែងឆ្លងកាត់រំងាប់មេរោគ មានបន្ទប់ផ្លាស់ប្តូរសម្លៀកបំពាក់មុននឹងចេញពីកសិដ្ឋានចិញ្ចឹមសត្វ មានបន្ទប់លាងសម្អាតដៃជើងមុននិងក្រោយចេញ-ចូលកសិដ្ឋានចិញ្ចឹមសត្វ

-មានកន្លែងសម្រាប់ស្តុកចំណីសត្វ

-មានបន្ទប់សម្រាប់ទុកដាក់សម្ភារបរិក្ខាពេទ្យ និងបសុឱសថស្របតាមបទដ្ឋានបច្ចេកទេស

-សាងសង់រោងសម្រាប់ចិញ្ចឹមសត្វតាមបទដ្ឋានបច្ចេកទេស

-មានការិយាល័យសម្រាប់មន្ត្រីបសុពេទ្យមានសមត្ថកិច្ច

-មានការិយាល័យធ្វើការងារសម្រាប់កសិដ្ឋានចិញ្ចឹមសត្វ និងបន្ទប់កម្មករនៅដាច់ដោយឡែកពីបរិវេណចិញ្ចឹមសត្វ

-មានអគារផ្ទេរសត្វចេញ-ចូលដាច់ដោយឡែកពីគ្នា

-រោងសម្រាប់ពិនិត្យព្យាបាលនិងអនុវត្តវិធានបសុព្យាបាល

-មានប្រព័ន្ធគ្រប់គ្រងកាកសំណល់តាមរយៈការសាងសង់អាងប្រព្រឹត្តិកម្មឬឡជីវឧស្ម័ន

-មានបន្ទប់ទឹកនិងបង្គន់អនាម័យ សម្រាប់បុរស នារី

-មានបន្ទប់សម្រាប់ទុកដាក់សម្ភារ ឧបករណ៍ប្រើប្រាស់ក្នុងកសិដ្ឋានចិញ្ចឹមសត្វ

-មានឡសម្រាប់ដុតកំទេចសាកសពសត្វនិងកាកសំណល់ដែលមានមេរោគ

-មានប្រភពទឹកស្អាតសម្រាប់ប្រើប្រាស់គ្រប់គ្រាន់

-ត្រូវមានអ្នកបច្ចេកទេសថ្នាក់បរិញ្ញាបត្រផលិតកម្មនិងបសុព្យាបាល ឬបរញ្ញាបត្រវិទ្យាសាស្ត្រសត្វ ឬបរិញ្ញាបត្រវេជ្ជសាស្ត្រសត្វឡើងទៅ ឬសញ្ញាបត្រសមមូល ដើម្បីទទួលខុសត្រូវការងារបច្ចេកទេសក្នុងកសិដ្ឋានចិញ្ចឹមសត្វ

-ត្រូវមានប្រព័ន្ធអត្តសញ្ញាណសត្វនៅក្នុងកសិដ្ឋាន

-ត្រូវផ្តល់របាយការណ៍ទៀងទាត់ជូនអង្គភាពផលិតកម្មនិងបសុព្យាបាលនូវស្ថិតិសត្វនៅក្នុងកសិដ្ឋាន ដំណើរការកសិដ្ឋាន និងស្ថានភាពជំងឺរៀងរាល់០៣ខែម្តង តាមរយៈអ្នកបច្ចេកទេសផលិតកម្មនិងបសុព្យាបាលប្រចាំការនៅកសិដ្ឋានចិញ្ចឹមសត្វ ដែលទទួលស្គាល់ដោយនាយកដ្ឋានផលិតកម្មនិងបសុព្យាបាល។

ជម្រើសទី២ ស្តីពីការរៀបចំប្រកាសស្តីពីការបង្កើតនិងការគ្រប់គ្រងកសិដ្ឋានចិញ្ចឹម ត្រូវបានសិក្សានិងវិភាគតាមលក្ខណៈវិទ្យាសាស្ត្រពីផលប៉ះពាល់លើបន្ទុកចំណាយ និងផលចំណេញនៃធុរកិច្ចនិងរដ្ឋាភិបាលៈ

### ៤.២.១.បន្ទុកចំណាយលើធុរកិច្ច

ដើម្បីអនុវត្តតាមបញ្ញត្តិកម្មថ្មីដែលតម្រូវឲ្យធុរកិច្ចបំពេញកាតព្វកិច្ចដូចមានចែងនៅក្នុងប្រការ៣, ៦, ៧, និងប្រការ១១ខាងលើ នោះធុរកិច្ច មានបន្ទុកចំណាយសរុបចំនួន៣៨.៩៦១.៨៩១ដុល្លារស្មើនឹង ៩៧.៥៥%នៃចំណាយសរុបទាំងធុរកិច្ចនិងរដ្ឋាភិបាល ក្នុងនោះកសិដ្ឋានចិញ្ចឹមសត្វមួយកន្លែង ត្រូវចំណាយជាមធ្យមអស់២៩.៦៩៧ដុល្លារ។ តាមការគណនា ធុរកិច្ចបានរងនូវបន្ទុកចំណាយបន្ថែមប្រមាណ ១១.៦៩៧ដុល្លារ ស្មើនឹង៣៩,៣៩% សម្រាប់ដំណើរការបើកកសិដ្ឋានចិញ្ចឹមសត្វមួយកន្លែង បើប្រៀបធៀបនឹងស្ថានភាពដើមគឺមុនពេលមិនទាន់បង្កើតប្រកាសស្តីពីការបង្កើត និងការគ្រប់គ្រងកសិដ្ឋានចិញ្ចឹមសត្វនេះ។ ចំណាយកើនឡើងដែលធៀបនឹងស្ថានភាពដើមប្រមាណ៣៩,៣៩%នោះដោយសារធុរកិច្ចត្រូវចំណាយបន្ថែមលើការសាងសង់ដូចជាអាងប្រព្រឹត្តិកម្ម ឬឡជីវឧស្ម័ន ឡុកម្ទេចសាកសព អគារផ្ទេរសត្វចេញ-ចូលដាច់ដោយឡែកពីគ្នា ចំណាយរដ្ឋបាលលើអ្នកបច្ចេកទេស កម្មករ និងការរៀបចំរបាយការណ៍ ជូនអង្គភាពមានសមត្ថកិច្ចនូវស្ថិតិសត្វនៅក្នុងកសិដ្ឋាន ដំណើរការកសិដ្ឋាន និងស្ថានភាពជំងឺរៀងរាល់០៣ខែម្តងជាដើម។ បើពិនិត្យពីបន្ទុកចំណាយនេះ ហាក់បីដូចជាខ្ពស់បន្តិច តែវានឹងធ្វើឲ្យកសិដ្ឋាននៅកម្ពុជា មានការគ្រប់គ្រងតាមបទដ្ឋានបច្ចេកទេសមួយច្បាស់លាស់ ធានានិងការពារបាននូវសុវត្ថិភាពនិងសុខភាពសាធារណៈ ពិសេសការការពារការរីករាលដាលនៃជំងឺឆ្លងសត្វ ដែលជាកត្តាប៉ះពាល់ធ្ងន់ធ្ងរដល់ផលិតកម្មសត្វ និងសេដ្ឋកិច្ចសង្គម។

### ៤.២.២.បន្ទុកចំណាយលើរដ្ឋាភិបាល

នៅក្នុងដំណើរការរៀបចំប្រកាសស្តីពីការបង្កើត និងការគ្រប់គ្រងកសិដ្ឋានចិញ្ចឹមសត្វ រដ្ឋ (ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ) បានរងនូវបន្ទុកចំណាយមានជាអាទ៍ ការរៀបចំសេចក្តីព្រាង ការពិគ្រោះយោបល់ ការងារផ្សព្វផ្សាយ ការចេញលិខិតអនុញ្ញាត និងការផលិតឯកសារ ( ពាក្យសុំបង្កើតនិងចុះបញ្ជីកសិដ្ឋានចិញ្ចឹមសត្វ) ការចុះត្រួតពិនិត្យនិងធ្វើវិធានបសុពេទ្យ ការងារគ្រប់គ្រងទិន្នន័យនិងការចុះតាមដានការអនុវត្តតាមកសិដ្ឋាន ដោយមានបន្ទុកចំណាយសរុប ៩៧៩.០៩៧ដុល្លារ ស្មើនឹង២,៤៥%នៃចំណាយសរុបទាំងធុរកិច្ចនិងរដ្ឋាភិបាល។ បើធៀបនឹងធុរកិច្ច រដ្ឋាភិបាល មានបន្ទុកចំណាយទាប។

### ៤.២.៣.អំពីផលចំណេញ

ការបង្កើតបញ្ញត្តិកម្មថ្មី ស្តីពីការបង្កើតនិងការគ្រប់គ្រងកសិដ្ឋានចិញ្ចឹមសត្វនេះឡើង បានបង្កើន និងបន្ថែមបន្ទុកចំណាយប្រមាណ៣៩,៣៩% ដល់ធុរកិច្ចសម្រាប់ដំណើរការបើកកសិដ្ឋានចិញ្ចឹមសត្វមួយកន្លែង បើប្រៀបធៀបនឹងស្ថានភាពដើមមុនពេលមិនទាន់បង្កើតប្រកាសស្តីពីការបង្កើត និងការគ្រប់គ្រងកសិដ្ឋានចិញ្ចឹមសត្វនេះ រីឯរដ្ឋក៏មានបន្ទុកចំណាយស្មើនឹង៩៧៩.០៩៧ដុល្លារក្នុងនោះ១ខែរដ្ឋត្រូវចំណាយអស់ប្រមាណ៨១.៥៩១ដុល្លារ។ តាមការវិភាគ ទាំងរដ្ឋនឹងធុរកិច្ច ឃើញថា មានបន្ទុកចំណាយខ្ពស់ ប៉ុន្តែប្រកាសនេះ នឹងនាំមកនូវផលចំណេញដល់សង្គមច្រើន មានជាអាទ៍៖

- លើកកម្ពស់ផលិតកម្មសត្វ

-ការការពារបរិស្ថាន និងទប់ស្កាត់បាននូវការរីករាលដាលនៃជំងឺឆ្លងពីសត្វទៅសត្វ និងពីសត្វទៅមនុស្ស

-ធ្វើឱ្យសាច់សត្វមានសុវត្ថភាព និងបង្កើនទំនុកចិត្តដល់អ្នកប្រើប្រាស់

-បង្កើនសមត្ថភាពប្រកួតប្រជែង នៃការចិញ្ចឹមសត្វក្នុងស្រុក ដើម្បីជំរុញផលិតកម្មសម្រាប់បំពេញតម្រូវការ ផ្គត់ផ្គង់ទីផ្សារក្នុងស្រុក និង ឈានទៅដល់ការនាំចេញនៅពេលអនាគត

-ធ្វើឱ្យមានប្រសិទ្ធភាព ដល់ការគ្រប់គ្រងស្ថិតិនៃការចិញ្ចឹមសត្វ និងបរិមាណសត្វ

-បង្កើតការងារក្នុងស្រុកជូនប្រជាពលរដ្ឋខ្មែរ ដែលកំពុងប្រឈមនឹងចលនាលំហូនៃពលករចំណាកស្រុក ទៅរកការងារធ្វើនៅក្រៅប្រទេស និងចូលរួមក្នុងការរក្សាកំណើនសេដ្ឋកិច្ចប្រចាំឆ្នាំ

-បង្កើនទំនុកចិត្តដល់អ្នកវិនិយោគក្នុងវិស័យចិញ្ចឹមសត្វ តាមរយៈការមានក្របខ័ណ្ឌច្បាប់មួយច្បាស់លាស់ សម្រាប់ធានា និងសម្រួលដល់ការប្រកបអាជីវកម្មរបស់ធុរកិច្ច

- ការងារគ្រប់គ្រងចំណូលក្នុងវិស័យចិញ្ចឹមសត្វ មានភាពងាយស្រួលនិងច្បាស់លាស់

- ធ្វើឲ្យកម្ពុជា អាចនាំចេញនូវផលិតផលសត្វ ចូលទៅក្នុងទីផ្សារអាស៊ានបាន នៅពេលកម្ពុជាបានបំពេញតាមទិសដៅសមាហរណកម្មអាស៊ានឆ្នាំ២០១៥ ដែលតម្រូវឲ្យប្រទេសក្នុងតំបន់អាស៊ាននីមួយៗ មានច្បាប់ស្តីពីការបង្កើតនិងការគ្រប់គ្រងកសិដ្ឋានចិញ្ចឹមសត្វ និងលិខិតបញ្ជាក់ការអនុវត្តល្អប្រសើរនៃកសិដ្ឋានចិញ្ចឹមសត្វ(Good Animal Husbandry Practice) ទើបអាចធ្វើអាជីវកម្មនាំចេញសាច់សត្វ ឬសត្វទៅលក់នៅក្នុងតំបន់អាស៊ានបាន។ ដូចនេះ ដើម្បីរត់ឲ្យទាន់សភាពការណ៍ក្នុងតំបន់ ពិសេសសមាហរណកម្មសេដ្ឋកិច្ចអាស៊ាន បានកំពុងតម្រូវឲ្យកម្ពុជាពង្រឹងសមត្ថភាពក្នុងក្របខ័ណ្ឌច្បាប់ ទើបអាចមានសមត្ថភាពប្រកួតប្រជែងសេដ្ឋកិច្ចទាំងក្នុងតំបន់ និងទាំងនៅកម្រិតអន្តរជាតិបាន។

តាមការវិភាគផលប៉ះពាល់ គេអាចសន្និដ្ឋានបានថា ជម្រើសទី២ មានបន្ទុកចំណាយខ្ពស់ចំពោះរដ្ឋនិងធុរកិច្ច ដែលក្នុងនោះ នៅឆ្នាំដំបូង ធុរកិច្ចបានចំណាយភាគច្រើនលើការសាងសង់ ប៉ុន្តែបើដកបន្ទុកចំណាយលើការសាងសង់នៅឆ្នាំដំបូងចេញ នោះកសិដ្ឋានមួយជាមធ្យមបានថយបន្ទុកចំណាយ មកនៅត្រឹមប្រមាណ៩.៥០០ដុល្លារ ស្មើនឹងប្រមាណ១៥,៩១%ប៉ុណ្ណោះ។ ទន្ទឹមជាមួយគ្នានេះដែរ គេក៏សង្កេតមានផលចំណេញចម្បងៗដល់សង្គមមានដូចជា ការការពារបរិស្ថាន និងទប់ស្កាត់បាននូវការរីករាលដាលនៃជំងឺឆ្លងសត្វ ការបង្កើតការងារក្នុងស្រុកជូនប្រជាពលរដ្ឋខ្មែរ ធ្វើឲ្យកម្ពុជាអាចនាំចេញនូវផលិតផលសត្វ ចូលទៅក្នុងទីផ្សារអាស៊ានបាន នៅពេលកម្ពុជា បានបំពេញតាមទិសដៅសមាហរណកម្មអាស៊ានឆ្នាំ២០១៥ ដែលតម្រូវឲ្យប្រទេសក្នុងតំបន់អាស៊ាននីមួយៗ មានច្បាប់ស្តីពីការបង្កើតនិងការគ្រប់គ្រងកសិដ្ឋានចិញ្ចឹមសត្វ និងលិខិតបញ្ជាក់ការអនុវត្តល្អប្រសើរនៃកសិដ្ឋានចិញ្ចឹមសត្វ(Good Animal Husbandry Practice) ទើបអាចធ្វើអាជីវកម្មនាំចេញសាច់សត្វ ឬសត្វទៅលក់នៅក្នុងតំបន់អាស៊ានបាន ពិសេសការចូលរួមអនុវត្តយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៣ របស់

រាជរដ្ឋាភិបាលដែលនៅក្នុងចតុកោណទី១ បានកំណត់អំពីការលើកស្ទួយវិស័យកសិកម្ម ក្នុងនោះ មាននិយាយពីការលើកកម្ពស់ចលនាចិញ្ចឹមសត្វ ឲ្យកាន់តែទូលំទូលាយ។

## ៥. ការពិគ្រោះយោបល់

ដើម្បីមានមូលដ្ឋានគ្រប់គ្រាន់ក្នុង ការវាយតម្លៃអំពីផលប៉ះពាល់លើសេចក្តីព្រាងប្រកាសស្តីពីការបង្កើតនិងការគ្រប់គ្រងកសិដ្ឋានចិញ្ចឹមសត្វនេះ ក្រុមRIA របស់ក្រសួង បានធ្វើការពិគ្រោះយោបល់ជាមួយអ្នកពាក់ព័ន្ធដោយទទួលបានមតិយោបល់ដូចតទៅ៖

### ៥.១. ពិគ្រោះយោបល់ជាមួយផ្នែកសាធារណៈ

**៥.១.១-ក្រុមORIAប្រចាំECOSSOC នៃទីស្តីការគណៈរដ្ឋមន្ត្រីៈ** សេចក្តីព្រាងប្រកាស ដែលក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានរៀបចំឡើងមកនេះ ពិតជាមានសារសំខាន់ក្នុងអន្តរកាល ដែលច្បាប់ស្តីពីសុខភាពសត្វនិងផលិតកម្មសត្វ នៅមិនទាន់បានអនុម័តដាក់ឲ្យអនុវត្ត។ ក្នុងន័យនេះ ក្រសួងកសិកម្មចាំបាច់ត្រូវមានលិខិតបទដ្ឋានគតិយុត្តណាមួយសម្រាប់ គ្រប់គ្រងការចិញ្ចឹមសត្វ។ ការចិញ្ចឹមសត្វនៅកម្ពុជា នៅមានកម្រិតទន់ខ្សោយ មិនទាន់អាចផ្គត់ផ្គង់ តម្រូវការសាច់សត្វក្នុងប្រទេសបាននៅឡើយ ជាហេតុធ្វើឲ្យមានការនាំចូលបរិមាណសាច់សត្វដ៏ច្រើនពីក្រៅប្រទេស។ ការពឹងផ្អែកលើការនាំចូល ដោយមិនជំរុញការលើកកម្ពស់ផលិតកម្មក្នុងស្រុកឲ្យបានខ្លាំងក្លា វាជាកត្តាមិនទាន់ឆ្លើយតបបានសមស្របក្នុងការចូលរួមនៅក្នុងកំណើនសេដ្ឋកិច្ចប្រចាំឆ្នាំពីវិស័យចិញ្ចឹមសត្វ ព្រោះប្រទេសកម្ពុជា ពិតជាមានសក្តានុពលខ្ពស់ក្នុងការចិញ្ចឹមសត្វ។ បច្ចុប្បន្ន វិស័យចញ្ចឹមសត្វ គេសង្កេតឃើញមានការចិញ្ចឹមច្រើនតែតាមបែបលក្ខណៈគ្រួសារ រីឯតាមលក្ខណៈពាក់កណ្តាលឧស្សាហកម្ម និងឧស្សាហកម្មឃើញមានចំនួនតិចតួចនៅឡើយ។

ចំពោះសេចក្តីព្រាងប្រកាសដែលក្រសួងគ្រោងនឹងបង្កើតនេះ មានគោលបំណងដោះស្រាយបញ្ហាចម្បងៗមានជាអាទិ៍ ការបង្កើនផលិតភាពសត្វ ការទប់ស្កាត់ការរីករាលជំងឺឆ្លងសត្វ ការការពារសុខភាពសត្វ សុខ-មាលភាពសត្វ សុខភាពសាធារណៈ និងការការពារបរិស្ថាន ដូចមានចែងនៅក្នុងប្រការ១នៃសេចក្តីព្រាង។ ស្មារតីនៃប្រកាសទាំងមូល មិនមានប្រការណាមួយ និយាយពីការបង្កើន ផលិតភាពសត្វនោះទេ តែខ្លឹមសារផ្តោតតែទៅលើការគ្រប់គ្រងការរីករាលដាលនៃជំងឺឆ្លងសត្វប៉ុណ្ណោះ។ ហេតុនេះ គួរមានប្រការណាមួយចែងអំពីការជំរុញផលិតកម្មសត្វ ដោយមានការលើកទឹកចិត្តពីរដ្ឋទៅដល់អ្នកចិញ្ចឹមសត្វផង ដើម្បីឲ្យប្រកាសនេះ មានខ្លឹមសារគ្រប់ជ្រុងជ្រោយ។ ទន្ទឹមនឹងនេះ ក៏ស្នើក្រសួងពិចារណារលើបន្ទុកចំណាយ ដែលអាចធ្វើឲ្យប៉ះពាល់ដល់ការប្រកបរបរចិញ្ចឹមសត្វរបស់ធុរកិច្ច។

**៥.១.២-ការិយាល័យផលិតកម្មនៃនាយកដ្ឋានផលិតកម្ម និងបសុព្យាបាល**

ការចិញ្ចឹមសត្វបច្ចុប្បន្ន យើងនៅមិនទាន់លិខិតបទដ្ឋានគតិយុត្ត សម្រាប់គ្រប់គ្រងនៅឡើយទេ។ អាជីវករដែលបានសុំច្បាប់ចិញ្ចឹមសត្វសព្វថ្ងៃ គឺដោយសារពួកគាត់ត្រូវការសុំវិញ្ញាបនបត្រអនាម័យសត្វក្នុងពេលដឹកជញ្ជូនសត្វប៉ុណ្ណោះ រីឯការប្រមូលកម្រៃនៃការចិញ្ចឹមសត្វទៀតសោធក៏មិនទាន់មានមូលដ្ឋានកំណត់ច្បាស់លាស់ដែរ។ តាមប្រកាសរួមស្តីពីការផ្តល់សេវាសាធារណៈរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ កសិដ្ឋានចិញ្ចឹមសត្វដែលមានច្បាប់អនុញ្ញាត ត្រូវបានគេបែងចែកជាកសិដ្ឋាន

ចិញ្ចឹមសត្វខ្នាតធំប្រភេទ «ក» និងកសិដ្ឋានចិញ្ចឹមសត្វខ្នាតមធ្យមប្រភេទ «ខ» ដើម្បីសម្រួលដល់ការប្រមូលចំណូលពីសេវាសាធារណៈ ដែលក្នុងនោះការសុំលិខិតអនុញ្ញាតបើកកសិដ្ឋានចិញ្ចឹមសត្វប្រភេទ«ក» មួយកន្លែងត្រូវបង់៨០០.០០០រៀល និងកសិដ្ឋានចិញ្ចឹមសត្វប្រភេទ «ខ» ថ្លៃ៥០០.០០០រៀល ។ ទោះបីថា មានកសិដ្ឋាន បែងចែកជាប្រភេទ«ក» និងប្រភេទ «ខ» ដូចកំណត់នៅក្នុងប្រកាសរួមក៏ពិតមែន តែវានៅមិនទាន់មានបញ្ញត្តិកម្មណាមួយចេញដោយរដ្ឋ កំណត់ពីលក្ខខណ្ឌ និងការសុំបង្កើតកសិដ្ឋានចិញ្ចឹមសត្វឲ្យបានច្បាស់លាស់នៅឡើយ ដែលជាប្រការដ៏លំបាកសម្រាប់សមត្ថកិច្ចក្នុងការគ្រប់គ្រងនៃការរីករាលដាលនៃជំងឺឆ្លង ផលប៉ះពាល់បរិស្ថាន និងបច្ចេកទេសនៃការចិញ្ចឹមជាដើម។ ម្យ៉ាងទៀត ការមិនមានបញ្ញត្តិកម្មសម្រាប់គ្រប់គ្រងការចិញ្ចឹម សត្វ បែបនេះ នឹងធ្វើឲ្យកម្ពុជា មិនអាចនាំចេញនូវផលិតផលសត្វចូលទៅក្នុងទីផ្សារអាស៊ានបាន ព្រោះតាមទិសដៅសមាហរណកម្មអាស៊ានឆ្នាំ២០១៥ បានតម្រូវឲ្យប្រទេសក្នុងតំបន់អាស៊ាននីមួយៗ មានច្បាប់ ស្តីពីការបង្កើតនិងការគ្រប់គ្រងកសិដ្ឋានចិញ្ចឹមសត្វ និងលិខិតបញ្ជាក់ការអនុវត្តល្អប្រសើរនៃកសិដ្ឋាន ចិញ្ចឹមសត្វ (Good Animal Husbandry Practice) នោះទើបប្រទេសជាសមាជិកនីមួយៗ អាចធ្វើអាជីវកម្មនាំចេញសាច់សត្វ ឬសត្វទៅលក់នៅក្នុងតំបន់អាស៊ានបាន។ ជាមួយគ្នានេះ នៅក្នុងសមាហរណកម្មសេដ្ឋកិច្ចអាស៊ានដែលឈានចូលមកដល់នៅត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៥នេះ ប្រទេសកម្ពុជា ចាំបាច់ត្រូវប្រកាសឲ្យប្រើ និងដាក់ឲ្យអនុវត្តនូវលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងជីវសុវត្ថិភាពនិងការចិញ្ចឹមសត្វល្អ (Good Farming Practices- GFP) ព្រោះវាជាឧបករណ៍ដ៏សំខាន់សម្រាប់ការទប់ស្កាត់និងការត្រួត-ពិនិត្យជំងឺសត្វនៅក្នុងប្រព័ន្ធផលិតកម្មសត្វ។

ដូច្នេះ ការរៀបចំប្រកាសស្តីពីការបង្កើតនិងការគ្រប់គ្រងកសិដ្ឋានចិញ្ចឹមសត្វនេះឡើង វាជាការអភិវឌ្ឍក្របខ័ណ្ឌគតិយុត្ត ដើម្បីគាំទ្រយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៣ របស់រាជរដ្ឋាភិបាលសម្រាប់នីតិកាលទី៥នៃរដ្ឋសភា ដែលមានចែងយ៉ាងច្បាស់នៅក្នុងមុំទី២ ស្តីពីការលើកកម្ពស់ការចិញ្ចឹមសត្វ និងវារីវប្បកម្មនៃចតុកោណទី១ ស្តីពីការលើកស្ទួយវិស័យកសិកម្ម និងក្នុងបរិបទដែលព្រះរាជាណាចក្រកម្ពុជាត្រូវបំពេញក្នុងក្របខ័ណ្ឌនៃអង្គការពាណិជ្ជកម្មពិភពលោក (WTO) អង្គការសុខភាពសត្វពិភពលោក (OIE) ការធ្វើសមាហរណកម្មកម្ពុជា ជាមួយអាស៊ាន(ASEAN) និងជាមួយបណ្តាប្រទេសក្នុងតំបន់ផងដែរ។ ដូចនេះ គួរក្រសួងជួយជំរុញការកសាងប្រកាសស្តីពីការបង្កើតនិង ការគ្រប់គ្រងកសិដ្ឋានចិញ្ចឹមសត្វឲ្យបានលឿន នៅពេលដែលច្បាប់ស្តីពីសុខភាពសត្វ និងផលិតកម្មសត្វ នៅមិនទាន់ត្រូវបានអនុម័តដាក់ឲ្យអនុវត្ត។

**៥.១.៣-អគ្គលេខាធិការរង ទទួលបន្ទុកការងារផលិតកម្មនិងបសុព្យាបាលនៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ:**

សេចក្តីព្រាងប្រកាសនេះ គួរអង្គភាពនាយកដ្ឋានផលិតកម្ម និងបសុព្យាបាល សិក្សាឲ្យបានស៊ីជម្រៅជាមួយនឹងលិខិតបទដ្ឋានគតិយុត្តនៃបណ្តាលប្រទេស ដែលគេធ្លាប់អនុវត្តលើការគ្រប់គ្រងការចិញ្ចឹមសត្វ ពិសេសច្បាប់ ឬអនុសញ្ញាអន្តរជាតិដែលពាក់ព័ន្ធនឹងវិស័យចិញ្ចឹមសត្វ ថាតើកសិដ្ឋានចិញ្ចឹមសត្វមួយត្រូវមានលក្ខខណ្ឌត្រូវបំពេញអ្វីខ្លះ។ បើពិនិត្យមួយត្រួសលើខ្លឹមសារនៃសេចក្តីព្រាងនេះ ហាក់ការឲ្យនិយមន័យពាក្យ « កសិដ្ឋាន »នៅមិនទាន់ច្បាស់ រីឯខ្លឹមសាររួមនៃសេចក្តីព្រាងប្រកាស ក៏នៅមិនទាន់ឆ្លើយតបទៅនឹងគោលបំណងដូចមានចែងក្នុងប្រការ១នៃសេចក្តីព្រាងនៅ

ឡើយ ។ ការរៀបចំប្រកាសនេះឡើងជាការល្អ នៅពេលដែលច្បាប់ស្តីពីផលិតកម្មសត្វ និងសុខភាពសត្វ នៅមិនទាន់បានអនុម័ត តែគួរពិនិត្យខ្លឹមសារ និងអត្ថន័យ នៃប្រកាសនេះ ឲ្យបានគ្រប់ជ្រុងជ្រោយដើម្បីងាយស្រួលយកទៅអនុវត្ត។

**៥.១.៤-សមត្ថកិច្ចនៃមន្ទីរកសិកម្ម នៃខេត្តកំពង់ស្ពឺ កំពង់ឆ្នាំង ព្រៃវែង កំពង់ចាម និងខេត្តរតនគិរី:**

បច្ចុប្បន្ន ការចិញ្ចឹមសត្វមានទ្រង់ទ្រាយជាលក្ខណ:គ្រួសារមានចំនួនច្រើន ដោយពុំមានច្បាប់អនុញ្ញាតពីសមត្ថកិច្ចជំនាញទេ រីឯការចិញ្ចឹមក្នុងរូបភាពជាកសិដ្ឋានមានច្បាប់អនុញ្ញាតពីសមត្ថកិច្ចជំនាញមានបរិមាណតិចតួចនៅក្នុងខេត្តនីមួយៗ ដែលជាមធ្យមអាចមានចំនួនពី២ទៅ៣កសិដ្ឋានប៉ុណ្ណោះក្នុងមួយខេត្ត ។ អ្នកចិញ្ចឹមសត្វបានស្នើសុំលិខិតអនុញ្ញាតទាំងអស់ ពុំមានលិខិតបទដ្ឋានគតិយុត្តណាមួយតម្រូវពួកគាត់សុំបង្កើតកសិដ្ឋានចិញ្ចឹមសត្វទេ។ តែការការដាក់ពាក្យសុំបង្កើតកសិដ្ឋានចិញ្ចឹមសត្វនេះ វាជាការព្រួតៗគ្នាតាមរយ:ការណែនាំរបស់មន្ទីរកសិកម្ម (ការិយាល័យផលិតកម្ម និងបសុព្យាបាល) ដែលតែងតែចុះផ្សព្វផ្សាយអំពីបច្ចេកទេសនៃការចិញ្ចឹមសត្វ ការគ្រប់គ្រងបរិស្ថាននិងជីវ-សុវត្ថិភាព។ជាធម្មតាការចិញ្ចឹមសត្វទោះបីមានការគ្រប់គ្រងបរិស្ថានបានល្អយ៉ាងណាក៏ដោយ វាតែងតែនៅមានក្លិន និងសម្រែកសត្វ ដែលអាចប៉ះពាល់ដល់ការរស់នៅរបស់ប្រជាពលរដ្ឋមិនខាន គ្រាន់តែតិច ឬច្រើនប៉ុណ្ណោះ។ កន្លងមក ករណីក្លិន និងសម្រែកសត្វដែលចេញពីកសិដ្ឋានចិញ្ចឹមសត្វ ធ្លាប់មានប្រជាពលរដ្ឋប្តឹងឲ្យអាជ្ញាធរមានសមត្ថកិច្ច ចាត់វិធានការដោះស្រាយ។ ក្នុងការចិញ្ចឹមនេះដែរ ការរីករាលនៃជំងឺភាគច្រើនកើតចេញពីការចិញ្ចឹមសត្វជាលក្ខណ:គ្រួសារ តែវាកម្រមានផ្ទុះចេញពីកសិដ្ឋានដែលមានច្បាប់ត្រឹមត្រូវ ព្រោះកសិដ្ឋានមានច្បាប់ត្រឹមត្រូវបានអនុវត្តនូវជីវសុវត្ថិភាពនិងវិធានបសុព្យា-បាលជាប្រចាំ។

ពាក់ព័ន្ធនឹងសេចក្តីព្រាងប្រកាសនេះ មន្ទីរកសិកម្ម សូមគាំទ្រចំពោះការរៀបចំប្រកាសស្តីពីការបង្កើត និងការគ្រប់គ្រងកសិដ្ឋានចិញ្ចឹមសត្វ ដែលមានវិសាលភាពគ្របដណ្តប់ដល់ការចិញ្ចឹមសត្វខ្នាតតូច តែគួរក្រសួងពិនិត្យលទ្ធភាពលើការកែសម្រួលមានជាអាទិ៍ ការចុះបញ្ជីកសិដ្ឋាន ពុំគួរចុះបញ្ជីនៅថ្នាក់ជាតិទាំងអស់នោះទេ ពាក់ព័ន្ធនឹងសុពលភាព៥ឆ្នាំនៃលិខិតអនុញ្ញាត ដែលមានចែងនៅត្រង់ប្រការ១១ គួរតែកាត់បន្ថយមកនៅត្រឹម១ឆ្នាំ ដើម្បីងាយស្រួលណែនាំដល់ម្ចាស់កសិដ្ឋានរៀងរាល់ឆ្នាំ សុំណូមពរក្រសួងចំពោះការចុះបញ្ជីកសិដ្ឋាន សូមកុំឲ្យមានការស្មុគស្មាញ ជាពិសេសត្រូវមានការលើកទឹកចិត្តដល់សហគមន៍អភិវឌ្ឍន៍កសិកម្ម។

តែដើម្បីឲ្យសេចក្តីព្រាងប្រកាសដែលក្រសួងគ្រោងនឹងដាក់ចេញនេះ មានខ្លឹមសារ និងអត្ថ-ន័យគ្រប់ជ្រុងជ្រោយសម្រាប់ងាយស្រួលយកទៅអនុវត្ត គួរតែមានការពិគ្រោះយោបល់បន្ថែមឲ្យបានលម្អិតជាមួយអង្គភាព និងសមត្ថកិច្ចពាក់ព័ន្ធក្រោមឱវាទក្រសួង ព្រោះខ្លឹមសាររួមនៃសេចក្តីព្រាងប្រកាសនៅមិនទាន់ឆ្លើយតបទៅនឹងគោលបំណងដូចមានចែងក្នុងប្រការ១នៃសេចក្តីព្រាងនៅឡើយ។

### ៥.២. ពិគ្រោះយោបល់ជាមួយផ្នែកឯកជនៈ

### ៥.២.១. កសិដ្ឋានចិញ្ចឹមមាន់សាច់ រការធំ ខេត្តកំពង់ស្ពឺ

កសិដ្ឋាននេះ បានបើកដំណើរការអាជីវកម្មអស់រយៈពេល៥ឆ្នាំមកហើយ នៅលើទីតាំងដីឡូតិ៍មួយកន្លែងទំហំ ៣៥ម៉ែត្រ គុណនឹង១២០ម៉ែត្រ ។ កសិដ្ឋាននេះ មានការអនុញ្ញាតពីអាជ្ញាធរមូលដ្ឋាន និងមន្ទីរកសិកម្មខេត្តកំពង់ស្ពឺ ហើយមានការចុះតាមដានស្ថានភាពជំងឺពីសមត្ថកិច្ចមន្ទីរកសិកម្មខេត្តជាប្រចាំ។ ក្នុងឆ្នាំដំបូង ម្ចាស់កសិដ្ឋានបានចំណាយលើការសាងសង់រោងចំនួន២ទំហំ(៩ម៉ែត្រគុណនឹង៦០ម៉ែត្រ) ស្មើនឹង១៨.០០០ដុល្លារ និងការចំណាយក្នុងការចិញ្ចឹមថៃទាំក្នុងរយៈពេល៦០ថ្ងៃអស់ចំនួន២៦.០៨០ដុល្លារ សម្រាប់ការទិញកូនមាន់ចំនួន៧.០០០ក្បាល ការទិញចំណី ប្រាក់ឈ្នួលកម្មករចំនួន០៤នាក់ ថ្នាំបំបាត់ក្លិន និងការសុំលិខិតអនុញ្ញាត។ ទន្ទឹមនឹងការចំណាយនេះ ម្ចាស់កសិដ្ឋានបានទទួលជាប្រាក់ចំណេញសមរម្យក្រោយពីកាត់កងជាមួយនឹងការចំណាយ។

នៅក្នុងដំណើរការចិញ្ចឹម ម្ចាស់កសិដ្ឋានអាចរកប្រាក់ចំណេញបានសមរម្យ ប៉ុន្តែការចិញ្ចឹមក៏មានការប្ដឹងពីអ្នកជិតខាង លើករណីក្លិនស្អុយនៃលាមកសត្វទៅសមត្ថកិច្ចនៅក្នុងវេទិកាសាធារណៈ។

### ៥.២.២. កសិដ្ឋានចិញ្ចឹមជ្រូក បេតាក្រូ (Betagro ) នៅខេត្តកំពង់ឆ្នាំង

កសិដ្ឋាននេះ បានបើកដំណើរការអាជីវកម្មអស់រយៈពេលជិត៥ឆ្នាំមកហើយ នៅលើទីតាំងដីមួយកន្លែងទំហំ ២០ហិកតា ។ កសិដ្ឋានជ្រូកនេះ មានការអនុញ្ញាតពីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងមានទីតាំងស្ថិតនៅស្រុកកំពង់ត្រឡាច ខេត្តកំពង់ឆ្នាំង។ បច្ចុប្បន្ន ក្រុមហ៊ុន បានចំណាយទុនប្រមាណជិត២០ លានដុល្លារ សម្រាប់ចិញ្ចឹមជ្រូកយកសាច់ និងជ្រូកមេសម្រាប់លក់កូន ដែលក្នុងមួយខែ អាចផលិតកូនជ្រូកសម្រាប់លក់ចែកចាយបាន៣.០០០ក្បាល។ ជាក់ស្តែង ក្រុមហ៊ុនបានចំណាយលើការសាងសង់ជ្រូកសាច់១២ រោងជ្រូកមេសម្រាប់ផលិតកូនជ្រូកចំនួន០៦ រោងជ្រូកបាចំនួន០១ ឃ្លាំងសម្រាប់ដាក់ចំណីសត្វ និងបសុឱសថ អគារស្នាក់នៅរបស់បុគ្គលិក កម្មករចំនួន២ខ្នង និងអគារសម្រាប់ជាការិយាល័យធ្វើការចំនួន០១ខ្នង។ ក្រុមហ៊ុន បានប្រើប្រាស់បុគ្គលិកចំនួន១៦នាក់ ដែលក្នុងម្នាក់ ទទួលបានប្រាក់ឈ្នួលចាប់ពី១៨០ដុល្លារឡើង និងមានកម្មករចំនួន៤៦នាក់ ដែលក្នុងម្នាក់ ទទួលបានប្រាក់ឈ្នួលប្រមាណ១៣៥ដុល្លារ ក្នុងនោះ អាហារនិងការស្នាក់នៅរបស់បុគ្គលិក និងកម្មករ ជាបន្ទុករបស់ក្រុមហ៊ុន។ កាកសំណល់នៃការចិញ្ចឹមសត្វ ត្រូវបានក្រុមហ៊ុន បង្ហូរចូលក្នុងអាងស្តុកទុកលាមក ដែលជាការគ្រប់គ្រងតាមបទដ្ឋានបច្ចេកទេសនៃការចិញ្ចឹមសត្វយ៉ាងត្រឹមត្រូវ។

ការបង្កើតប្រកាសស្តីពីការបង្កើតនិងការគ្រប់គ្រងកសិដ្ឋានចិញ្ចឹមសត្វនេះឡើង ក្រុមហ៊ុនមិនមានយោបល់អ្វីជំទាស់ទេ វាជាការល្អ។

### ៥.២.៣. អគ្គនាយកនៃក្រុមហ៊ុន ហ៊ាង អាញ អណ្តូងមាស នៅខេត្តរតនគិរី

កសិដ្ឋាននេះ បង្កើតឡើងក្នុងពាក់កណ្តាលឆ្នាំ២០១៤ លើទីតាំងដីសម្បទានសេដ្ឋកិច្ចចំនួន ៩.៤៧០ ហិកតា ដែលក្រុមហ៊ុននេះ បានដាំដូងប្រេងរួចចំនួន ៦.៦០០ ហិកតា។ ក្រុមហ៊ុន បានវិនិយោគចិញ្ចឹមគោលើផ្ទៃដីចំនួន៥០ ហិកតា ក្នុងដីសម្បទានសេដ្ឋកិច្ច ដែលរាជរដ្ឋាភិបាលប្រគល់ឲ្យ ដោយមានអាជ្ញាប័ណ្ណចិញ្ចឹមគោត្រឹមត្រូវពីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។ ការចិញ្ចឹម គោនេះ ក្រុមហ៊ុនមានគម្រោងដាក់ទុនប្រមាណ២៥០លានដុល្លារ លើការវិនិយោគហេដ្ឋារចនាសម្ព័ន្ធនិងផលិតកម្មសត្វគោ ឲ្យបាន៥០.០០០ក្បាល។ បច្ចុប្បន្ន ក្រុមហ៊ុន មានទុនប្រមាណ ២៥ លានដុល្លារ សម្រាប់ចិញ្ចឹមគោជាក់ស្តែងចំនួន២.០០០ក្បាល ដោយក្នុងនោះបានចំណាយលើ ការសាងសង់ ក្រោល ដាំស្មៅនិងពោត សម្រាប់ជាចំណីសត្វ និងបំពាក់ម៉ាស៊ីនកិនចំណីសត្វ។ ចំពោះទីផ្សារលក់ គោចេញក្រុមហ៊ុនបានចុះកិច្ចសន្យាជាមួយប្រទេសវៀតណាម ក្នុងការនាំចេញសត្វគោ ដែលបាន ចិញ្ចឹមក្នុងកសិដ្ឋាននេះទៅប្រទេសវៀតណាម។ ក្រុមហ៊ុន បានប្រើប្រាស់អ្នកបច្ចេកទេសចំនួន ០៦នាក់ ដែលអ្នកបច្ចេកទេសម្នាក់ទទួលបានប្រាក់ឈ្នួលចំនួន៦៥០ដុល្លារ និងមានកម្មករចំនួន១៦៨នាក់ ដែលកម្មករម្នាក់ទទួលបានប្រាក់ឈ្នួលចំនួន២០០ដុល្លារ។ កាកសំណល់នៃការចិញ្ចឹមសត្វ ក្រុមហ៊ុន ប្រើប្រាស់ជាជីធម្មជាតិ សម្រាប់ដំណាំដូងប្រេង និងចំការស្មៅចំណីសត្វ ចំណែកឯកាក ផ្លែដូងប្រេង ត្រូវបានកែច្នៃជាចំណីសម្រាប់ឲ្យគោស៊ីវិញ។

ការរៀបចំឲ្យមានច្បាប់ សម្រាប់គ្រប់គ្រងកសិដ្ឋានចិញ្ចឹមសត្វ វាជាការយកចិត្តទុកដាក់ និងចេតនាល្អរបស់រាជរដ្ឋាភិបាល ដើម្បីគាំទ្រដល់ការវិនិយោគឲ្យមានច្បាប់ត្រឹមត្រូវ និងធ្វើឲ្យអ្នករកស៊ីមានលទ្ធភាពប្រកបអាជីវកម្មដោយស្មើភាពគ្នាចំពោះមុខច្បាប់។ ដូចនេះ ការបង្កើតប្រកាសស្តីពីការបង្កើត និងការគ្រប់គ្រងកសិដ្ឋានចិញ្ចឹមសត្វនេះឡើង ក្រុមហ៊ុនមិនមានយោបល់អ្វីជំទាស់ទេ វាជាការល្អ។

### ៥.២.៤. លោក អ៊ីវ សៀងឡេង ម្ចាស់កសិដ្ឋានចិញ្ចឹមមាន់ថ្មគោលនៅខេត្តកំពង់ចាម

កសិដ្ឋាននេះ បានបង្កើតឡើង០៥ឆ្នាំមកហើយ លើទីតាំងដីឡូត៍មួយកន្លែងមានទំហំ៦០ម៉ែត្រគុណនឹង៧៥ម៉ែត្រ ដែលមានលំនៅដ្ឋានប្រជាពលរដ្ឋរស់នៅជុំវិញចំងាយប្រមាណ១០០ម៉ែត្រពីកសិដ្ឋានដោយមានការអនុញ្ញាតពីអាជ្ញាធរមូលដ្ឋាន និងមន្ទីរកសិកម្មខេត្តកំពង់ចាម ហើយមានការចុះតាមដានស្ថានភាពជំងឺពីក្រុមហ៊ុនផ្តល់ពូជ (CP) និងមន្ទីរកសិកម្មខេត្តជាប្រចាំ។ ក្នុងឆ្នាំដំបូង ម្ចាស់កសិដ្ឋានបានចំណាយលើការសាងសង់រោងចំនួន១ ការដាក់មាន់មេពូជចំនួន៦.០០០ក្បាល ការទិញចំណីប្រាក់ឈ្នួលកម្មករចំនួន០៤នាក់ ថ្នាំបំពាត់ក្លិន និងការសុំលិខិតអនុញ្ញាត ដែលមានចំណាយទាំងអស់

ចំនួន១៩៩.២៨០ដុល្លារ។ ទន្ទឹមនឹងការចំណាយនេះ ម្ចាស់កសិដ្ឋានបានទទួលចំណូលត្រឡប់មកវិញតាមរយៈ លក់ស៊ុតក្នុង១ខែបាន១២.០០០ដុល្លារ លក់លាមកមាន់ក្នុង១ខែបាន៤៨០ដុល្លារ និងលក់មេមាន់ជម្រុះក្រោយពីការចិញ្ចឹមបាន៥៤សប្តាហ៍បាន ១៧.៣២៥ដុល្លារ ដែលក្នុងឆ្នាំដំបូង គាត់ទទួលបានចំណូលចំនួន១៦៧.០៨៥ដុល្លារ។ នៅក្នុងដំណើរការចិញ្ចឹម ម្ចាស់កសិដ្ឋានអាចរកប្រាក់ចំណេញបានសមរម្យ ប៉ុន្តែការចិញ្ចឹមក៏មានការប្តឹងពីអ្នកជិតខាង លើករណីក្លិនរបស់លាមកសត្វ ទៅសមត្ថកិច្ចដែលជាកត្តាប៉ះពាល់ដល់អាជីវកម្មប្រចាំថ្ងៃ តែក្រោយពីសមត្ថកិច្ចនៃមន្ទីរបរិស្ថានចុះមកពិនិត្យឃើញថាមិនមានបញ្ហាក្លិនស្អុយធ្ងន់ធ្ងរទេ គ្រាន់តែណែនាំឲ្យបាញ់ថ្នាំបំបាត់ក្លិនបន្ថែម ។ ដើមឡើយ ចំពោះការគ្រប់គ្រងលាមកសត្វ គឺទុកដាក់ក្នុងឡជីវឧស្ម័ន តែបច្ចុប្បន្ន ឡជីវឧស្ម័នបានខូច ឯលាមកមាន់ក៏ត្រូវបានគេទិញយកទៅដាក់ដំណាំជារៀងរាល់ថ្ងៃ ដោយមិនមានលាមកមាន់សល់នៅក្នុងកសិដ្ឋានទៀតទេ។

ការចំណាយលើលិខិតអនុញ្ញាតសម្រាប់ខ្នាតមធ្យម « ខ » មានតម្លៃ៨០០.០០០រៀលគឺសមរម្យក្នុងរយៈពេល៥ឆ្នាំ តែអាចមានបញ្ហាប្រឈមអំពីការរកទីតាំងចិញ្ចឹមថ្មីឲ្យឆ្ងាយពីទីប្រជុំជន និងសមស្រប។ ការរៀបចំឲ្យមានច្បាប់សម្រាប់គ្រប់គ្រងកសិដ្ឋានចិញ្ចឹមសត្វនេះ ជាការល្អដែរ ដើម្បីឲ្យអ្នករកស៊ីមានលទ្ធភាពប្រកបអាជីវកម្មដោយស្មើភាពគ្នាចំពោះមុខច្បាប់។

**៥.២.៥. កសិដ្ឋានចិញ្ចឹមជ្រូកសាច់ រ័ត្ន សុភ័ព្វ នៅខេត្តកំពង់ចាម**

កសិដ្ឋានចិញ្ចឹមជ្រូកនេះ ស្ថិតនៅក្នុងភូមិស្រែក ឃុំស្រែក ស្រុកកំពង់សៀម មានចំងាយប្រមាណ១៥គីឡូម៉ែត្រពីក្រុងកំពង់ចាមនិងបានបង្កើតឡើងក្នុងឆ្នាំ២០១៤ លើទីតាំងដីឡូត៍មួយកន្លែងមានទំហំ៦០មគុណនឹង១០០ម៉ែត្រ នៅដាច់ឆ្ងាយពីលំនៅដ្ឋានប្រជាពលរដ្ឋ។ កសិដ្ឋានចិញ្ចឹមជ្រូកសាច់ រ័ត្ន សុភ័ព្វបានចុះកិច្ចសន្យាជាមួយក្រុមហ៊ុន CP ចិញ្ចឹមជ្រូកសាច់ប្រវាស់ ( ស៊ីឈ្នួលចិញ្ចឹមឲ្យក្រុមហ៊ុន ) ដោយម្ចាស់កសិដ្ឋានគ្រាន់តែមានដី(ទីតាំង) បង្កើតហេដ្ឋារចនាសម្ព័ន្ធដូចជារោង និងទ្រុង និងកម្លាំងពលកម្មសម្រាប់ថែទាំសត្វ និងសុំលិខិតអនុញ្ញាតបើកកសិដ្ឋាន ចំណែកឯពូជជ្រូក បសុឱសថនិងការចាក់វ៉ាក់សាំង ចំណី និងបច្ចេកទេស វាជាបន្ទុកចំណាយរបស់ក្រុមហ៊ុនCP ។ ចំពោះការគ្រប់គ្រងលាមកជ្រូក និងកាកសំណល់នៃការចិញ្ចឹមវិញ ត្រូវបានគេបង្ហូរដាក់ចូលវាលទំនាប ដោយមិនទាន់មានអាងស្តុកលាមក ឬឡជីវឧស្ម័ននៅឡើយទេ។ ការបង្ហូរលាមកជ្រូក និងកាកសំណល់នៃការចិញ្ចឹមចូលវាលទំនាបនេះ បានបណ្តាលឲ្យមានប្រជាពលរដ្ឋមួយគ្រួសារ បានប្តឹងអំពីកាកសំណល់ និងទឹកស្អុយពីលាមកជ្រូកដែលហូរចូលស្រែរបស់កសិករនៅផ្នែកខាងក្រោម តែក្រោយពីសមត្ថកិច្ចចុះមកពិនិត្យឃើញថាមិនមានបញ្ហាធ្ងន់ធ្ងរទេ ។

កសិដ្ឋានបានបង្កើតឡើង មានការអនុញ្ញាតត្រឹមត្រូវពីអាជ្ញាធរមូលដ្ឋាននិងមន្ទីរកសិកម្មខេត្តកំពង់ចាម ហើយមានការចុះតាមដានស្ថានភាពជំងឺពីក្រុមហ៊ុនផ្តល់ពូជ CP ក្នុងមួយសប្តាហ៍ម្តង ហើយមន្ទីរកសិកម្មចុះពិនិត្យរៀងរាល់មួយខែម្តង។ ម្ចាស់កសិដ្ឋាន បានចំណាយលើការសាងសង់រោង២ខ្នង អស់៩០.០០០ដុល្លារ កម្មករចំនួន០២នាក់ អស់១.៨០០ដុល្លារក្នុងរយៈពេល៦ខែ និងការសុំលិខិតអនុញ្ញាតមានសុពលភាព៥ឆ្នាំអស់១០០ដុល្លារ ដែលមានចំណាយទាំងអស់ ចំនួន៩១.៩០០ដុល្លារ។

ម្ចាស់កសិដ្ឋានទទួលបានចំណូលតាមរយៈកិច្ចសន្យាដែលបានព្រមព្រៀងជាមួយក្រុមហ៊ុន CP ដោយទទួលបានសេវាឬថ្លៃចិញ្ចឹម ១៥០រៀលក្នុងមួយគីឡូក្រាម នៃទម្ងន់ជ្រូកពេលចាប់លក់ បើការថែទាំបានល្អដោយមិនមានជ្រូកងាប់ នោះម្ចាស់កសិដ្ឋានទទួលបានប្រាក់លើកទឹកចិត្តបន្ថែម៥០០រៀលក្នុងមួយគីឡូក្រាម។ ប្រាក់លើកទឹកចិត្តនេះ ម្ចាស់កសិដ្ឋាន ទទួលបានតាមសមាមាត្រនៃអត្រាសត្វងាប់ក្នុងមួយវគ្គនៃការចិញ្ចឹម។ ថ្លៃឈ្នួលចិញ្ចឹមមធ្យម ដែលម្ចាស់កសិដ្ឋានទទួលបាន គឺ ៥៥០រៀលក្នុងមួយគីឡូក្រាមក្នុងរង្វង់អត្រាសត្វងាប់៥% ។ ជ្រូកមួយក្បាលចាប់លក់មានទម្ងន់៨០គីឡូក្រាម ក្នុងនោះដែរ គេអាចចិញ្ចឹមជ្រូកបានបីដង ក្នុងរយៈពេលពីរឆ្នាំ ។ ជាមធ្យម ម្ចាស់កសិដ្ឋានរកបានចំណូល ៥.៨៣០ដុល្លារ ក្នុងរយៈពេល ០៦ខែនៃការចាប់លក់ម្តងៗ។

ម្ចាស់កសិដ្ឋាន បានគាំទ្រចំពោះការរៀបចំឲ្យមានច្បាប់ សម្រាប់គ្រប់គ្រងកសិដ្ឋានចិញ្ចឹមសត្វនេះ ដើម្បីឲ្យអ្នករកស៊ី មានលទ្ធភាពប្រកបអាជីវកម្មដោយស្មើភាពគ្នាចំពោះមុខច្បាប់ ហើយបានសំណូមពរដល់រាជរដ្ឋាភិបាល(ក្រសួងកសិកម្ម រុក្ខាប្រមាញ់និងនេសាទ ) សូមជួយផ្នែកបច្ចេកទេសតាមរយៈការផ្តល់នូវវគ្គបណ្តុះបណ្តាលស្តីពីបច្ចេកទេសនៃការចិញ្ចឹមសត្វ។

### ៥.៣. ប្រជាពលរដ្ឋដែលមានលំនៅដ្ឋាន ឬដីស្រែ នៅជុំវិញកសិដ្ឋានចិញ្ចឹមសត្វ

តាមការជួបពិភាក្សា និងពិគ្រោះយោបល់ជាមួយប្រជាពលរដ្ឋចំនួន០៧គ្រួសារ ដែលមានលំនៅស្ថាននៅចម្ងាយពី៥០ ទៅ១៥០ម៉ែត្រពីកសិដ្ឋានចិញ្ចឹមជ្រូក និងមាន់ បានឲ្យដឹងថា ពួកគាត់មានការសប្បាយរីករាយ និងសូមគាំទ្រចំពោះគោលបំណងរបស់រដ្ឋដែលគ្រោងរៀបចំអត្ថបទច្បាប់ សម្រាប់គ្រប់គ្រងការចិញ្ចឹមសត្វនេះឡើង ដើម្បីការពារបរិស្ថានរស់នៅរបស់ប្រជាពលរដ្ឋ។ បច្ចុប្បន្ន ការចិញ្ចឹមសត្វធ្វើអាជីវកម្ម ដូចជាការចិញ្ចឹមជ្រូក មាន់ ទា វាតែងតែបានធ្វើឲ្យរំខានដល់ការរស់នៅខ្លាំងណាស់ ហើយពួកគេ ក៏បានសំណូមពរដល់អាជ្ញាធរមានសមត្ថកិច្ចឲ្យមានវិធានការដោះស្រាយចំពោះកសិដ្ឋានចិញ្ចឹមសត្វជ្រូក មាន់ទា ដែលមានបរិស្ថានមិនល្អ ដូចជាមានក្លិនស្អុយ មានរុយច្រើន កាកសំណល់ បង្ហូរចូលប្រឡាយទឹក ផ្លូវដើរ ឬស្រែ ពិសេសសំឡេងសត្វស្រែកទាំងយប់ និងថ្ងៃ ដែលបានប៉ះពាល់ការរស់នៅប្រចាំថ្ងៃ។

ក្រោយពីបានជួបពិគ្រោះយោបល់ជាមួយសមត្ថកិច្ចសាធារណៈ តំណាងនៃផ្នែកឯកជន និងជាមួយប្រជាពលរដ្ឋរួចមក ក្រុមការងារ បានធ្វើសេចក្តីសន្និដ្ឋានលើការពិគ្រោះយោបល់ដូចខាងក្រោម៖

១- សេចក្តីព្រាងប្រកាសស្តីពីការបង្កើត និងការគ្រប់គ្រងកសិដ្ឋានចិញ្ចឹមសត្វ ពិតជាមានសារៈសំខាន់ក្នុងការបំពេញតាមលក្ខខណ្ឌនៃសមាហរណកម្មអាស៊ានក្នុងឆ្នាំ២០១៥ និងជាពិសេសដើម្បីអនុវត្តឲ្យសម្រេចនូវយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៣ របស់រាជរដ្ឋាភិបាលដែលនៅក្នុងចតុកោណទី១ បានកំណត់អំពីការលើកស្ទួយវិស័យកសិកម្ម ក្នុងនោះមាននិយាយពីការលើកកម្ពស់ចលនាចិញ្ចឹមសត្វឲ្យកាន់តែទូលំទូលាយផងនោះ ។

២-នៅក្នុងខេត្ត រាជធានីនីមួយៗ កសិដ្ឋានចិញ្ចឹមសត្វដែលមានលិខិតអនុញ្ញាត មានចំនួនប្រហែល០៣កសិដ្ឋានប៉ុណ្ណោះ។

៣-ផ្នែកសាធារណៈពាក់ព័ន្ធ បានគាំទ្រលើការរៀបចំប្រកាសស្តីពីការបង្កើត និងការគ្រប់គ្រងកសិដ្ឋានចិញ្ចឹមសត្វ ដែលមានវិសាលភាពគ្របដណ្តប់ដល់ការចិញ្ចឹមសត្វខ្នាតតូច តែសំណូមពរដល់ក្រសួងមេត្តាពិចារណានូវករណីនៃការចុះបញ្ជីកកសិដ្ឋាន ពុំគួរចុះបញ្ជីនៅថ្នាក់ជាតិទាំងអស់នោះទេ រីឯសុពលភាពលិខិតអនុញ្ញាតមានរយៈពេល៥ឆ្នាំក្នុងសេចក្តីព្រាងប្រកាសនៅត្រង់ប្រការ៦ សុំកាត់បន្ថយមកនៅត្រឹម១ឆ្នាំ ដើម្បីងាយស្រួលណែនាំដល់ម្ចាស់កសិដ្ឋានមួយឆ្នាំម្តង។ តែដើម្បីឲ្យសេចក្តីព្រាងប្រកាសដែលក្រសួងគ្រោងនឹងដាក់ចេញនេះ មានខ្លឹមសារ និងអត្ថន័យគ្រប់ជ្រុងជ្រោយ សម្រាប់ងាយស្រួលយកទៅអនុវត្ត គួរតែមានការពិគ្រោះបល់បន្ថែមឲ្យបានលម្អិតជាមួយអង្គភាព និងសមត្ថកិច្ចពាក់ព័ន្ធក្រោមឱវាទក្រសួង ព្រោះខ្លឹមសាររួមនៃសេចក្តីព្រាងប្រកាសនៅមិនទាន់ឆ្លើយតបទៅនឹងគោលបំណងដូចមានចែងក្នុងប្រការ១ នៃសេចក្តីព្រាងនៅឡើយ។ រីឯផ្នែកឯកជនដែលបានជួបពិគ្រោះយោបល់ ក៏បានសំដែងការគាំទ្រការបង្កើតឲ្យមានច្បាប់ក្នុងវិស័យចិញ្ចឹមសត្វ ដើម្បីឲ្យអ្នករកស៊ីមានលទ្ធភាពប្រកបអាជីវកម្មចិញ្ចឹមសត្វដោយស្មើភាពគ្នាចំពោះមុខច្បាប់។ ប៉ុន្តែ ស្នើក្រសួងពិនិត្យបញ្ហាប្រឈមនៃការតម្រូវឲ្យផ្លាស់ប្តូរទីតាំងចិញ្ចឹមទៅឲ្យឆ្ងាយពីទីប្រជុំជន ក្រោយពីប្រកាសនេះចេញដាក់ឲ្យអនុវត្តដែលអាចជាការធ្វើឲ្យមានការចំណាយបន្ថែមច្រើនសម្រាប់អ្នករកស៊ី។

៤-បច្ចុប្បន្ន ការចិញ្ចឹមសត្វមានទ្រង់ទ្រាយជាលក្ខណៈគ្រួសារមានចំនួនច្រើន ហើយពុំមានច្បាប់អនុញ្ញាតពីសមត្ថកិច្ចជំនាញ រីឯការចិញ្ចឹមក្នុងរូបភាពជាកសិដ្ឋានមានច្បាប់អនុញ្ញាតពីសមត្ថកិច្ចជំនាញមានបរិមាណតិចតួចនៅក្នុងខេត្តនីមួយៗ ដែលជាមធ្យមអាចមានចំនួនពី២ទៅ៣កសិដ្ឋានប៉ុណ្ណោះក្នុងមួយខេត្ត ។

បង្កើតនិងការគ្រប់គ្រងកសិដ្ឋានចិញ្ចឹមសត្វឲ្យបានលឿន នៅពេលដែលច្បាប់ស្តីពីផលិតកម្មសត្វ និងសុខភាពសត្វនៅមិនទាន់ ត្រូវបានអនុម័ត។

៥-បច្ចេកទេសនៃការចិញ្ចឹមសត្វរបស់កសិករ ឬអាជីវករចិញ្ចឹមសត្វនៅមានកម្រិត ដោយពួកគាត់បានសំណូមពរដល់រាជរដ្ឋាភិបាល(ក្រសួងកសិកម្ម រុក្ខាប្រមាញ់និងនេសាទ) សូមជួយផ្នែកបច្ចេកទេស តាមយៈការផ្តល់នូវវគ្គបណ្តុះបណ្តាលស្តីពីបច្ចេកទេសនៃការចិញ្ចឹមសត្វ។

៦-ការគ្រប់គ្រងលាមកនិងកាកសំណល់សត្វមិនបានត្រឹមត្រូវតាមបទដ្ឋានបច្ចេកទេស បានបង្កជាផលប៉ះពាល់ដល់ការរស់នៅរបស់ប្រជាពលរដ្ឋ ជាក់ស្តែងតែងតែមានបណ្តឹងចំពោះក្លិនស្អុយពីកាកសំណល់និងទឹកស្អុយពីលាមកមាន់ ឬលាមកជ្រូក។ កសិដ្ឋានខ្លះ បានស្ថិតនៅឆ្ងាយពីភូមិដ្ឋានប្រជាពលរដ្ឋ តែលាមកសត្វ និងកាកសំណល់មិនបានទុកដាក់ និងគ្រប់គ្រងតាមបទដ្ឋានបច្ចេកទេសដែលបានធ្វើឲ្យហូរចូលស្រែ ឬបឹងបួរធម្មជាតិនៅជុំវិញកសិដ្ឋាន បង្កជាផលប៉ះពាល់ដល់បរិស្ថាន ។

## ៦-សន្និដ្ឋាន

ផ្អែកតាមការពិគ្រោះយោបល់ ការសិក្សា និងការវិភាគអំពីផលប៉ះពាល់ដូចបានអធិប្បាយខាងលើ គេអាចសន្និដ្ឋានបានថា ជម្រើសទី២ (សេចក្តីព្រាងប្រកាសស្តីពីការបង្កើត និងការគ្រប់កសិដ្ឋានចិញ្ចឹមសត្វ) មានបន្ទុកចំណាយខ្ពស់ទាំងរដ្ឋនិងធុរកិច្ចបើធៀបនឹងស្ថានភាពដើម តែបញ្ញត្តិកម្មនេះនឹងធ្វើឲ្យកសិដ្ឋានចិញ្ចឹមសត្វនៅកម្ពុជា មានការគ្រប់គ្រងតាមបទដ្ឋានបច្ចេកទេសមួយច្បាស់លាស់ ធានានិងការពារបាននូវសុវត្ថិភាព និងសុខភាពសាធារណៈ ពិសេសការការពារបរិស្ថាននិងការទប់ស្កាត់ការរីករាលដាលនៃជំងឺឆ្លងសត្វ ដែលជាកត្តាប៉ះពាល់ធ្ងន់ធ្ងរដល់ផលិតកម្មសត្វ និងសេដ្ឋកិច្ចសង្គម។ លើសពីនេះ វាក៏នឹងផ្តល់ប្រយោជន៍ដល់សង្គមជាតិមានជាអាទិ៍ ចូលរួមក្នុងកំណើនសេដ្ឋកិច្ចជាតិ តាមរយៈការបង្កើនសមត្ថភាពប្រកួតប្រជែង នៃការចិញ្ចឹមសត្វក្នុងស្រុក ដើម្បីជំរុញផលិតកម្មសត្វសម្រាប់បំពេញតម្រូវការផ្គត់ផ្គង់ទីផ្សារក្នុងស្រុក និងឈានទៅដល់ការនាំចេញនៅពេលអនាគត។ ម្យ៉ាងវិញទៀតបញ្ញត្តិកម្មនេះ ពិតជាធ្វើឲ្យវិស័យចិញ្ចឹមសត្វនៅកម្ពុជាអាចពង្រីកខ្លួនពីការចិញ្ចឹមទ្រង់ទ្រាយតូចៗដែលគ្មានការគ្រប់គ្រងប្រមូលផ្តុំទៅជាការចិញ្ចឹមតាមលក្ខណៈពាក់កណ្តាលឧស្សាហកម្ម និងឧស្សាហកម្ម ដើម្បីជួយបំពេញតម្រូវការសាច់សត្វក្នុងប្រទេសដែលកំពុងកើនឡើងខ្ពស់ហួសពីការផ្គត់ផ្គង់ និងព្រមទាំងជួយៈ

១-ធ្វើឱ្យសាច់សត្វមានសុវត្ថភាព និងបង្កើនទំនុកចិត្តដល់អ្នកប្រើប្រាស់។

២-ធ្វើឱ្យមានប្រសិទ្ធភាព ដល់ការគ្រប់គ្រងស្ថិតិនៃការចិញ្ចឹមសត្វ និងបរិមាណសត្វ ដើម្បីងាយស្រួលធ្វើការព្យាករណ៍ពីតម្រូវការនិងការផ្គត់ផ្គង់សាច់សត្វក្នុងស្រុក។

៣-បង្កើតការងារក្នុងស្រុកជូនប្រជាពលរដ្ឋខ្មែរ ដែលកំពុងប្រឈមនឹងចលនាលំហូរនៃពលករចំណាកស្រុក ទៅរកការងារធ្វើនៅក្រៅប្រទេស និងចូលរួមក្នុងការរក្សាកំណើនសេដ្ឋកិច្ចប្រចាំឆ្នាំ។

៤-បង្កើនទំនុកចិត្តដល់អ្នកវិនិយោគក្នុងវិស័យចិញ្ចឹមសត្វ តាមរយៈការមានក្របខ័ណ្ឌច្បាប់មួយច្បាស់លាស់ សម្រាប់ធានា និងសម្រួលដល់ការប្រកបអាជីវកម្មរបស់ធុរកិច្ច។

៥- គ្រប់គ្រងចំណូលក្នុងវិស័យចិញ្ចឹមសត្វ មានភាពងាយស្រួល ច្បាស់លាស់ និងមានតម្លាភាព។

៦- ធ្វើឲ្យកម្ពុជា អាចនាំចេញនូវផលិតផលសត្វ ចូលទៅក្នុងទីផ្សារអាស៊ានបាន នៅពេលកម្ពុជាបានបំពេញតាមទិសដៅសមាហរណកម្មអាស៊ានឆ្នាំ២០១៥ ដែលតម្រូវឲ្យប្រទេសក្នុងតំបន់អាស៊ាននីមួយៗ មានច្បាប់ស្តីពីការបង្កើតនិងការគ្រប់គ្រងកសិដ្ឋានចិញ្ចឹមសត្វនិងលិខិតបញ្ជាក់ការអនុវត្តល្អប្រសើរនៃការចិញ្ចឹមសត្វ(Good Animal Husbandry Practice) ទើបអាចធ្វើអាជីវកម្មនាំចេញសាច់សត្វ ឬសត្វទៅលក់នៅក្នុងតំបន់អាស៊ានបាន។ ដូចនេះ ដើម្បីរត់ឲ្យទាន់សភាពការណ៍ក្នុងតំបន់ ពិសេសសមាហរណកម្មសេដ្ឋកិច្ចអាស៊ាន បានកំពុងតម្រូវឲ្យកម្ពុជាពង្រឹងសមត្ថភាពក្នុងក្របខ័ណ្ឌច្បាប់ ទើបអាចមានសមត្ថភាពប្រកួតប្រជែងសេដ្ឋកិច្ចទាំងក្នុងតំបន់ និងទាំងនៅកម្រិតអន្តរជាតិបាន។

ដូច្នេះ ការរៀបចំប្រកាសស្តីពីការបង្កើតនិងការគ្រប់គ្រងកសិដ្ឋានចិញ្ចឹមសត្វនេះឡើង វាជាការអភិវឌ្ឍក្របខ័ណ្ឌគតិយុត្ត ដើម្បីគាំទ្រយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៣ របស់រាជរដ្ឋាភិបាលសម្រាប់នីតិកាលទី៥នៃរដ្ឋសភា ដែលមានចែងយ៉ាងច្បាស់នៅក្នុងមុំទី២ ស្តីពីការលើកកម្ពស់ការចិញ្ចឹមសត្វ និងវារីវប្បកម្មនៃចតុកោណទី១ ស្តីពីការលើកស្ទួយវិស័យកសិកម្ម និងក្នុងបរិបទដែលព្រះរាជាណាចក្រកម្ពុជា ត្រូវបំពេញក្នុងក្របខ័ណ្ឌនៃអង្គការពាណិជ្ជកម្មពិភពលោក(WTO) អង្គការសុខភាពសត្វពិភពលោក (OIE) ការធ្វើសមាហរណកម្មកម្ពុជា ជាមួយអាស៊ាន(ASEAN) និងជាមួយ បណ្តាប្រទេសក្នុងតំបន់ផងដែរ។

យោងបរិបទនៃក្របខ័ណ្ឌនៃអង្គការពាណិជ្ជកម្មពិភពលោក(WTO) អង្គការសុខភាពសត្វពិភពលោក (OIE) និងការធ្វើសមាហរណកម្មកម្ពុជាជាមួយអាស៊ាន(ASEAN) និងជាមួយបណ្តាប្រទេសក្នុងតំបន់ និងផ្អែកតាមទិដ្ឋភាពជាក់ស្តែងដែលច្បាប់ស្តីពីសុខភាពសត្វ និងផលិតកម្មសត្វ នៅមិនទាន់ត្រូវបានអនុម័តដាក់ឲ្យអនុវត្តនៅឡើយនោះ ប្រកាសស្តីពីការបង្កើត និងការគ្រប់គ្រងកសិដ្ឋានចិញ្ចឹមសត្វពិតជាមានសារៈសំខាន់និងជាកាលៈទេសៈមួយសមស្រប សម្រាប់ក្រសួងរៀបចំដំណើរការសម្រេចដាក់ឲ្យអនុវត្ត។ ប៉ុន្តែ ដើម្បីឲ្យសេចក្តីព្រាងប្រកាសស្តីពីការបង្កើត និងការគ្រប់គ្រងកសិដ្ឋានចិញ្ចឹមសត្វនេះ កាន់តែមានខ្លឹមសារគ្រប់ជ្រុងជ្រោយ និងឲ្យស្របតាមសំណូមពររបស់ធុរកិច្ច និងកាត់បន្ថយបាននូវបន្ទុកចំណាយមិនចាំបាច់មួយចំនួន គួរក្រសួងពិនិត្យពិចារណា និងកែសម្រួលនូវខ្លឹមសារមួយចំនួនដូចតទៅ៖

ក-គួរអង្គភាពនាយកដ្ឋានផលិតកម្ម និងបសុព្យាបាល សិក្សាឲ្យបានស៊ីជម្រៅជាមួយនឹងលិខិតបទដ្ឋានគតិយុត្តនៃបណ្តាប្រទេស ដែលគេធ្លាប់អនុវត្តលើការគ្រប់គ្រងការចិញ្ចឹមសត្វ ពិសេសច្បាប់ ឬអនុសញ្ញាអន្តរជាតិដែលពាក់ព័ន្ធនឹងវិស័យចិញ្ចឹមសត្វ ហើយតើកសិដ្ឋានចិញ្ចឹមសត្វមួយត្រូវមានលក្ខខណ្ឌត្រូវបំពេញអ្វីខ្លះ។ ចំពោះការបែងចែកប្រភេទកសិដ្ឋានហាក់មាននិយមន័យ មិនទាន់ច្បាស់ រីឯខ្លឹមសាររួមនៃសេចក្តីព្រាងប្រកាស ក៏នៅមិនទាន់ឆ្លើយតបទៅនឹងគោលបំណងដូចមានចែងក្នុងប្រការ១នៃសេចក្តីព្រាងនៅ ឡើយ ។

ខ- ការបង្កើត និងការចុះបញ្ជីកសិដ្ឋាន គួរប្រតិភូកម្មសមត្ថកិច្ចឲ្យមន្ទីរកសិកម្មរាជធានី ខេត្តជាអ្នកសម្រេចចំពោះកសិដ្ឋានខ្នាតមធ្យមនិងខ្នាតតូច រីឯខ្នាតឧស្សាហកម្មជាសិទ្ធិសម្រេចរបស់ថ្នាក់ជាតិ។

ពាក់ព័ន្ធនឹងសុពលភាព៥ឆ្នាំនៃលិខិតអនុញ្ញាតដែលមានចែងនៅត្រង់ប្រការ១១ គួរតែកាត់បន្ថយ ព្រោះវាមានរយៈពេលវែងពេក អាចបង្កការលំបាកដល់ការគ្រប់គ្រង។

គ-ចំពោះលក្ខខ័ណ្ឌតម្រូវដែលមានចែងក្នុងប្រការ៣, ៦, ៧, ១១ គួររៀបចំតម្រូវទៅតាមខ្នាតរបស់កសិដ្ឋាននីមួយៗ មិនគួរកំណត់លក្ខខ័ណ្ឌរួមតែមួយ សម្រាប់តម្រូវឲ្យកសិដ្ឋានទាំងបីប្រភេទបំពេញលក្ខខ័ណ្ឌដូចៗគ្នានោះទេ។

## ៧- ការអនុវត្ត តាមដាន និងការវាយតម្លៃ

ក្រោយពេលប្រកាសស្តីពីការបង្កើត និងការគ្រប់គ្រងកសិដ្ឋានចិញ្ចឹមសត្វ ត្រូវបានក្រសួងប្រកាសដាក់ឲ្យអនុវត្តជាផ្លូវការ នោះវិធានការជំរុញការអនុវត្តច្បាប់ត្រូវអនុវត្តតាមដំណាក់កាលសំខាន់ដូចតទៅ៖

**ក-ដំណាក់កាលផ្សព្វផ្សាយប្រកាស:** សមត្ថកិច្ចនាយកដ្ឋានផលិតកម្មនិងបសុព្យាបាលនៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ នឹងបង្កើតកម្មវិធីផ្សព្វផ្សាយខ្លឹមសារប្រកាសស្តីពីការបង្កើតនិងការគ្រប់គ្រងកសិដ្ឋានចិញ្ចឹមសត្វ។ នាយកដ្ឋានផលិតកម្មនិងបសុព្យាបាល ចុះសហការជាមួយមន្ទីរកសិកម្មរាជធានីខេត្តនិងអាជ្ញាធររដ្ឋបាលថ្នាក់ក្រោមជាតិ ផ្សព្វផ្សាយឲ្យបានទូលំទូលាយដល់អ្នកចិញ្ចឹមសត្វនៅក្នុងរយៈពេល០៣ខែ តាមកម្មវិធីផ្សព្វផ្សាយដែលបានរៀបចំឡើង។

**ខ-ដំណាក់កាលតាមដានការអនុវត្តច្បាប់:** ក្នុងអំឡុងពេលនៃការប្រតិបត្តិបញ្ញត្តកម្មនេះ ដើម្បីលើកកម្ពស់តម្លាភាព និងអភិបាលកិច្ចល្អ ត្រូវឲ្យមានការចុះធ្វើអធិការកិច្ចបួនដងក្នុងមួយឆ្នាំ ក្នុងនោះមានការចុះពិនិត្យតាមដានដោយមន្ត្រីមានសាមត្ថកិច្ចថ្នាក់រាជធានីខេត្តចំនួនបីដង និងការធ្វើអធិការកិច្ចដោយថ្នាក់ក្រសួងនៅក្នុងប្រចាំឆ្នាំនីមួយៗនៅតាមកសិដ្ឋានចិញ្ចឹមសត្វ។

**គ-ដំណាក់កាលសិក្សានិងវាយតម្លៃការអនុវត្តច្បាប់:** បញ្ញត្តិកម្មនេះ នឹងត្រូវត្រួតពិនិត្យឡើងវិញក្នុងអំឡុងពេល៥ឆ្នាំ តាមរយៈការបង្កើតយន្តការសិក្សានិងវាយតម្លៃការអនុវត្តដោយផ្តោតជាសំខាន់លើព័ត៌មានត្រឡប់ពីធុរកិច្ច ( ម្ចាស់កសិដ្ឋាន ) ការវិវត្តន៍នៃសេដ្ឋកិច្ច និងនយោបាយរបស់រាជរដ្ឋាភិបាល។